គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក

FAMILY Microfinance Plc.

# របាយការណ៍ប្រចាំឆ្នាំ

## ២០២៤

www.familymfi.com.kh

# ចក្ខុវិស័យ និង បេសកកម្ម

## បេសកកម្ម

ផ្តល់ដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និង ផ្តល់សេវាល្អដើម្បីលើកកម្ពស់ជីវភាពរស់នៅឲ្យកាន់តែប្រសើរឡើង។

## ចក្ខុវិស័យ

ជាជម្រើសទី១ និង ជាដៃគូយុទ្ធសាស្រ្តដ៏ល្អបំផុត ដែលផ្តល់ជូននូវដំណោះស្រាយហិរញ្ញវត្ថុ ប្រកបដោយភាពច្នៃប្រឌិត និងបង្កើតតម្លៃប្រកបដោយនិរន្តរភាពសម្រាប់ភាគទុនិក បុគ្គលិក និងសហគមន៍។

## តម្លៃស្នូល

**F** ភាពយុត្តិធម៌ ការវិនិច្ឆ័យដោយបើកចំហរ និងតម្លាភាព។

**A** គណនេយ្យភាព ទទួលខុសត្រូវខ្ពស់ជាមួយការយកចិត្តទុកដាក់។

**M** សីលធម៌ អនុវត្តសីលធម៌ខ្ពស់ និងបទដ្ឋានសីលធម៌។

**I** ភាពសុចរិត កសាងភាពសុចរិត និងភាពស្មោះត្រង់ក្នុងទស្សនៈរបស់បុគ្គលិក។

**L** ភាពស្មោះត្រង់ អ្នកកាន់តែជឿទុកចិត្ត ការរីកចម្រើនកាន់តែច្រើន។

**Y** បាទ/ចា បាទ/ចា! យើងអាចធ្វើបាន។

# មាតិកា


## I. ព័ត៌មានសាជីវកម្មរបស់យើង ១

១. អំពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក ១

២. ក្រុមប្រឹក្សាភិបាល ២

៣ .រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រង ៤

៤. សេចក្ដីថ្លែងការណ៍ពីប្រធានក្រុមប្រឹក្សាភិបាល ៧

## II. ការគ្រប់គ្រងប្រតិបត្តិការ និងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ១០

១. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន និងគណៈគ្រប់គ្រង ១០

២. គណៈគ្រប់គ្រង ១៥

៣. ផលិតផល និងសេវាកម្ម ១៩

៤. សកម្មភាពសង្គមរបស់ក្រុមហ៊ុន ២៥

## III. សមិទ្ធផលហិរញ្ញវត្ថុរបស់យើង ២៨

១. សេចក្ដីសង្ខេបអំពីសមិទ្ធផល ២៨

២. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ៣២

៣. របាយការណ៍ហិរញ្ញវត្ថុសវនកម្មឯករាជ្យ ៣៥

៤. របាយការណ៍សនវកម្មហិរញ្ញវត្ថុ ៣៩

# I. ព័ត៌មានសាជីវកម្មរបស់យើង




## ១. អំពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ត្រូវបានបង្កើតឡើងក្នុងខែតុលា ឆ្នាំ ២០១៨ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជនដែលគ្រប់គ្រងដោយធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់ដំណោះស្រាយហិរញ្ញវត្ថុដល់បុគ្គល និងសហគ្រាសក្នុងប្រទេសកម្ពុជា។ យើងប្តេជ្ញាផ្តល់ដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិតដល់បុគ្គល និងសហគ្រាសនានានៅទូទាំងប្រទេសកម្ពុជា ដែលផ្នែកមួយដែលជួយជំរុញដល់កំណើនសេដ្ឋកិច្ច ជាពិសេសវិស័យហិរញ្ញវត្ថុ។ ម្ចាស់ភាគហ៊ុនរបស់យើងទាំងពីរ គឺ**លោក វូ ចិន** និង **លោក វូ ស៊ុយុន** គឺជាពាណិជ្ជករតៃវ៉ាន់ដំបូងដែលឈានមុខគេក្នុងប្រទេសកម្ពុជា។ ពួកគាត់ទាំងពីររូបបានប្រកបអាជីវកម្មនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង ២០ ឆ្នាំមកហើយ។ ដោយសារតែភាពរីកចម្រើននៃអាជីវកម្មនៅកម្ពុជា និងការរួមចំណែកដ៏ធំរបស់ពួកគាត់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម

នៃប្រទេសកម្ពុជា លោក វូ ចិន ទទួលបានសញ្ជាតិកម្ពុជា និងបានចាប់ផ្តើមបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ផ្តល់នូវសេវាកម្មល្អបំផុតជូនអតិថិជនដូចជា ការការពារអតិថិជន ផ្តល់នូវការប្រកួតប្រជែង ការច្នៃប្រឌិតផលិតផលកម្ចីដល់ពាណិជ្ជករ សហគ្រិន អាជីវករ កសិករ និងអាជីវកម្មគ្រួសារផ្ទាល់ខ្លួន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ត្រូវបានបង្កើតឡើងជាមួយនឹងតម្លៃស្នូលរបស់យើង ដើម្បីជួយប្រជាជនក្រីក្រដែលមានការលំបាកក្នុងការស្នើសុំសេវាហិរញ្ញវត្ថុពីធនាគារពាណិជ្ជ ដើម្បីជាទុនបន្ថែមសម្រាប់ដំណើរការ និងពង្រីកអាជីវកម្មរបស់ពួកគាត់។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី មានបុគ្គលិកដែលមានជំនាញវិជ្ជាជីវៈ និងបទពិសោធន៍ ដែលអាចជួយឱ្យអតិថិជន និងដៃគូរបស់យើងសម្រេចបាននូវអាជីវកម្មរបស់គាត់។

## ២. ក្រុមប្រឹក្សាភិបាល



**លោក វូ ចិន**

ប្រធានក្រុមប្រឹក្សាភិបាល

**លោក វូ ចិន** គឺជាប្រធានក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី តាំងពីឆ្នាំ ២០១៨។ លោកបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យហ្វ្រីហ្វិត ក្នុងប្រទេសអូស្ត្រាលីជំនាញពាណិជ្ជកម្មអន្តរជាតិ។ លោកបានចូលរួមសន្និសីទក្នុង និងក្រៅប្រទេសជាច្រើនផងដែរ មានដូចជាកិច្ចប្រជុំលើកទី ៣០ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍ឧស្សាហកម្មនិងពាណិជ្ជកម្ម ហើយលោកបានឈ្នះពានរង្វាន់ជាច្រើននៅក្រៅប្រទេសក្នុងឆ្នាំ២០១៨ ដែលជាពានរង្វាន់ឆ្នើមបំផុតមួយ នៃសហគ្រាសឆ្នើមទាំង១០ ក្នុងកោះតៃវ៉ាន់ ដែលមានឈ្មោះថា Golden Peak Award ជំនាន់ទី១៩។ ក្រៅពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី លោក វូ ចិន ក៏ជាគណៈគ្រប់គ្រងអាជីវកម្ម និងក្រុមហ៊ុនវិនិយោគជាច្រើន រួមមានក្រុមហ៊ុន តៃវ៉ាន់ ជី ឈី ខូអិលធីឌី, ក្រុមហ៊ុនវៀតណាម ហ្វូខិស, ក្រុមហ៊ុនជេអិល អភិវឌ្ឍន៍ ខូអិលធីឌី, SHINESTONE PLC, សមាគមកម្ពុជាសប្បុរសធម៌ ជេអិល និង ក្រុមហ៊ុនប៉ៃលវ៉ាន់រ៉ូសាច អិលធីឌី។ បទពិសោធន៍ដ៏ទូលំទូលាយ និងចក្ខុវិស័យយុទ្ធសាស្ត្ររបស់លោក បានរួមចំណែកដល់ភាពជោគជ័យ និងការរីកចម្រើននៃសហគ្រាស ឧស្សាហកម្មផ្សេងៗ។



**លោក វូ ស៊ូយុន**

សមាជិកក្រុមប្រឹក្សាភិបាល

**លោក វូ ស៊ូយុន** គឺជាសមាជិកក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វាមីលី ចាប់តាំងពីឆ្នាំ២០១៨។ បន្ថែមពីលើតួនាទីរបស់លោកនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វាមីលី លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនជាច្រើនរួមទាំងក្រុមហ៊ុនសាជីវកម្ម ដូចជា ក្រុមហ៊ុន ម៉ាត ស៊ុ បាយអូតិចណូឡូជី, សមាគមសប្បុរសធម៌ ជេ អិល កម្ពុជា និង ក្លឹប រ៉ុតធីរី នៃតៃចុង តៃស៊ីន។ លោកធ្លាប់កាន់តំណែងជាអ្នកដឹកនាំសំខាន់ៗ បម្រើការជាអនុប្រធានទូទៅនៃក្រុមហ៊ុន តៃវ៉ាន់ ជី ឈី ខូអិលធីឌី និងជាអ្នកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន ម៉ាត ស៊ុ ប្រូភើធីខូអិលធីឌី។ លើសពីនេះទៅទៀត លោកបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យហ្គ្រីហ្វីត ក្នុងប្រទេសអូស្ត្រាលី ជំនាញផ្នែកទីផ្សារ និងប្រព័ន្ធផ្សព្វផ្សាយទៀតផង។



**លោក កៅ ចុងហាវ**

អភិបាលឯករាជ្យ

**លោក កៅ ចុងហាវ** គឺជាអភិបាលឯករាជ្យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី។ លោកមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងវិស័យធនាគារនៅក្រៅប្រទេស ជាពិសេសនៅកោះតៃវ៉ាន់។ ជំនាញរបស់លោកគឺពង្រឹងទិសដៅយុទ្ធសាស្ត្រ និងអភិបាលកិច្ចរបស់ក្រុមប្រឹក្សាភិបាល។ មុនពេលចូលបម្រើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វាមីលី លោក **កៅ ចុងហាវ** បានបំពេញតួនាទីជាក្រុមប្រឹក្សានៃស្ថាប័នហិរញ្ញវត្ថុជាច្រើន រួមទាំងមូលនិធិសហគ្រាសធុនតូច និងមធ្យមតៃវ៉ាន់ និងធនាគារតៃវ៉ាន់ Securities ។ លោកក៏បានកាន់តួនាទីប្រតិបត្តិសំខាន់ៗផងដែរ រួមទាំងអគ្គនាយករងនៃក្រុមហ៊ុន Taiwan Ji Qi Shoe Co., Ltd. និង Jing-Du Construction Co., Ltd. ព្រមទាំងជានាយកប្រតិបត្តិនៃសមាគមសប្បុរសធម៌ JL Cambodia ផងដែរ។ លើសពីនេះ លោកបំពេញតួនាទីជាប្រធានសាខានៅធនាគារ Land Bank of Taiwan។

## ៣. រចនាសម្ព័ន្ធរបស់ក្រុមប្រឹក្សាភិបាល និង គណៈគ្រប់គ្រង



## ❖ គណៈកម្មាធិការសវនកម្ម

ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានបានបង្កើតគណៈកម្មាធិការមួយដែលត្រូវបានទទួលស្គាល់ថាជាគណៈកម្មាធិការសវនកម្មផ្ទៃក្នុង។ គណៈកម្មាធិការនេះ ត្រូវបានបង្កើតឡើងដើម្បីធានាថា អភិបាលកិច្ចសាជីវកម្មប្រកបដោយសុវត្ថិភាពជាមួយនឹងសិទ្ធិអំណាចដើម្បីអនុវត្តតាមលក្ខខណ្ឌដែលបានកំណត់។ ពាក់ព័ន្ធនឹងគណៈកម្មាធិការសវនកម្មផ្ទៃក្នុងនេះ មានតួនាទីត្រួតពិនិត្យរាល់ព័ត៌មានហិរញ្ញវត្ថុ របស់គ្រឹះស្ថានជូនភាគទុនិក បានពេញលេញ មានតម្លាភាព ដែលអាចជឿទុកចិត្តបាន និងទាន់ពេលវេលា។

### កិច្ចប្រជុំ:

- ការប្រជុំនៃគណៈកម្មាធិការត្រូវធ្វើឡើងយ៉ាងហោចណាស់ឱ្យបាន៤ដងក្នុងមួយឆ្នាំ។
- ប្រធានគណៈកម្មាធិការអាចស្នើសុំប្រជុំបន្ថែមតាមតម្រូវការ ប្រសិនបើចាំបាច់។
- ប្រធានសវនកម្មផ្ទៃក្នុង ត្រូវបញ្ជូនរបាយការណ៍ទៅគណៈកម្មាធិការសវនកម្ម យ៉ាងហោចណាស់មួយត្រីមាសម្តង នូវព័ត៌មានពាក់ព័ន្ធនឹងគ្រឹះស្ថាន។
- ការប្រជុំអាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ឬជួបដោយផ្ទាល់ ដើម្បីអាចផ្លាស់ប្តូរយោបល់ និងពិភាក្សាសម្រេច។

### សមាជិកភាព:

គណៈកម្មាធិការត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ដោយមានសមាជិកយ៉ាងតិចបំផុត ៣ រូប និងច្រើនបំផុត៥ រូប។ ប្រធាននៃគណៈកម្មាធិការនេះ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យរបស់ក្រុមហ៊ុន ហើយគ្រប់សមាជិកទាំងអស់ក៏ឯករាជ្យដែរ។

សមាជិកគណៈកម្មាធិការសវនកម្មរួមមានដូចខាងក្រោម:

- អភិបាលឯករាជ្យ : ប្រធាន
- សមាជិកក្រុមប្រឹក្សាភិបាល : សមាជិក
- ប្រធានសវនកម្មផ្ទៃក្នុង : សមាជិក

## ❖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានបានបង្កើតគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ដើម្បីបំពេញតាមតម្រូវការអភិបាលកិច្ច ក្នុងការអនុវត្តន៍នៅក្នុងស្ថាប័ន។ គណៈកម្មាធិការនេះនឹងជួយក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យក្របខ័ណ្ឌ គ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម រួមមាន៖ យុទ្ធសាស្ត្រ គោលការណ៍ នីតិវិធី និងប្រព័ន្ធគ្រប់គ្រង។ លើសពីនេះគណៈកម្មាធិការនេះអាចជួយក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការដទៃទៀតរបស់ខ្លួនដែលត្រួតពិនិត្យបញ្ហាទាក់ទងនឹងការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ជាក់លាក់នៅក្នុងស្ថាប័នទាំងមូល និងហានិភ័យគ្រប់ប្រភេទ។

### កិច្ចប្រជុំ:

ការប្រជុំនៃគណៈកម្មាធិការត្រូវធ្វើឡើងយ៉ាងហោចណាស់ឱ្យបាន២ដងក្នុងមួយឆ្នាំ។ ប្រធានក្រុមប្រឹក្សានៃគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម អាចធ្វើការកោះប្រជុំបន្ថែមប្រសិនបើចាំបាច់។

### សមាជិកភាព:

គណៈកម្មាធិការនេះត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល និងមានសមាជិក ៣ រូប។ ប្រធាន និងសមាជិកត្រូវតែឯករាជ្យនៅក្នុងស្ថាប័ន។

សមាជិកគណៈកម្មាធិការហានិភ័យរួមមាន:

- អភិបាលឯករាជ្យ : ប្រធាន
- សមាជិកក្រុមប្រឹក្សាភិបាល : សមាជិក
- ប្រធានប្រតិបត្តិតាម : សមាជិក

## ❖ គណៈកម្មាធិការតម្លៃការ និងតែងតាំង

ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានបានបង្កើតគណៈកម្មាធិការតម្លៃការ និងតែងតាំង ដើម្បីបំពេញតាមតម្រូវការអភិបាលកិច្ចក្នុងការអនុវត្តន៍នៅក្នុងស្ថាប័ន។ គណៈកម្មាធិការនេះ នឹងជួយក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យការអនុវត្តន៍គោលការណ៍បុគ្គលិក និងនីតិវិធីនៅក្នុងស្ថាប័នរួមទាំងប្រាក់ឈ្នួល និងការកសាងសមត្ថភាពសម្រាប់ថ្នាក់គ្រប់គ្រង បុគ្គលិក និងណែនាំរាល់ការផ្លាស់ប្តូរផ្សេងៗ ។

### កិច្ចប្រជុំ:

ការប្រជុំនៃគណៈកម្មាធិការត្រូវធ្វើឡើងយ៉ាងហោចណាស់ឱ្យបាន៣ដងក្នុងមួយឆ្នាំ។ ប្រធាននៃគណៈកម្មាធិការតម្លៃការ និងតែងតាំងអាចធ្វើការកោះប្រជុំបន្ថែមប្រសិនបើចាំបាច់។

### សមាជិកភាព:

សមាជិកគណៈកម្មាធិការតម្លៃការ និងតែងតាំងរួមមានដូចខាងក្រោម:

- អភិបាលឯករាជ្យ : ប្រធាន
- សមាជិកក្រុមប្រឹក្សាភិបាល : សមាជិក
- ប្រធានធនធានមនុស្ស និងរដ្ឋបាល : សមាជិក

# ៤. សេចក្តីថ្លែងការណ៍ពីប្រធានក្រុមប្រឹក្សាភិបាល



សេដ្ឋកិច្ចពិភពលោកបន្តកើនឡើងក្នុងអត្រា ៣.២ ភាគរយក្នុងកំឡុងឆ្នាំ ២០២៤ និងឆ្នាំ ២០២៥ ដោយមានកំណើនដូចនៅក្នុងឆ្នាំ ២០២៣ ។ ប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍមានការកើនឡើនយ៉ាងយឺត ដែលកំណើនត្រូវបានគេរំពឹងថានឹងកើនឡើងពី ១.៦ ភាគរយនៅឆ្នាំ ២០២៣ ទៅ ១.៧ ភាគរយនៅឆ្នាំ ២០២៤ និង ១.៨ ភាគរយក្នុងឆ្នាំ ២០២៥ ហើយវាធ្វើឱ្យមានការធ្លាក់ចុះនៃកំណើននៅក្នុងទីផ្សារ និងសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍពី ៤.៣ ភាគរយក្នុងឆ្នាំ ២០២៣ ដល់ ៤.២ ភាគរយក្នុងឆ្នាំ ២០២៤ និង ២០២៥ ។ អតិផរណាសកលត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះជាលំដាប់ ពី ៦.៨ ភាគរយក្នុងឆ្នាំ ២០២៣ ទៅ ៥.៩ ភាគរយនៅឆ្នាំ ២០២៤ និង ៤.៥ ភាគរយនៅឆ្នាំ ២០២៥ ដោយសេដ្ឋកិច្ចប្រទេសអភិវឌ្ឍនឹងរក្សាបានកម្រិតអតិផរណាជាទីផ្សារដែលកំពុងរីកចម្រើននិងសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍ។ អតិផរណាស្នូលជាទូទៅត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះបន្តិចម្តងៗ។ សេដ្ឋកិច្ចសកលនៅតែមានភាពរឹងមាំ ទោះបីជាធនាគារកណ្តាលមានការដំឡើងអត្រាការប្រាក់ ដើម្បីស្តារស្ថិរភាពតម្លៃក៏ដោយ។

នៅឆ្នាំ ២០២៤ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានបង្ហាញពីភាពធន់ ជាមួយនឹងការព្យាករណ៍កំណើនពី ៥.៣% ទៅ ៦.០%។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានរក្សាការព្យាករណ៍កំណើនរបស់ខ្លួននៅកម្រិត ៥.៨% សម្រាប់ឆ្នាំ ២០២៤ និង ៦.០% សម្រាប់ឆ្នាំ ២០២៥ ដោយសន្មតថាស្ថិរភាពនេះកើតឡើងដោយសារមានការនាំចេញ និងការងើបឡើងវិញនៃវិស័យទេសចរណ៍។ ទោះបីជាសេដ្ឋកិច្ចកម្ពុជាមានការកើនឡើងក៏ដោយ នៅឆ្នាំក្នុង២០២៤ វិស័យអចលនទ្រព្យ ទេសចរណ៍ និងអាជីវកម្មខ្នាតតូចរបស់កម្ពុជាដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ គឺនៅតែជួបប្រទះនឹងបញ្ហាប្រឈមដែលសល់ពីជំងឺរាតត្បាតកូវីដ-១៩ ដែលប៉ះពាល់ដល់គន្លងនៃការងើបឡើងវិញនៃវិស័យទាំងនោះ។ ដើម្បីសម្រួលដល់ស្ថានភាពក៏ដូចជាគាំទ្រការងើបឡើងវិញនៃវិស័យខាងលើ នៅចុងខែសីហា ឆ្នាំ ២០២៤ ធនាគារជាតិនៃកម្ពុជាបានចេញនូវសេចក្តីណែនាំថ្មីសម្រាប់ការរៀបចំឥណទានឡើងវិញដោយបន្ធូរបន្ថយតម្រូវការនៃការស្នើសុំហិរញ្ញវត្ថុ។ វិធានការថ្មីទាំងនេះនឹងចូលជាធរមានចាប់ពីខែកញ្ញា ឆ្នាំ ២០២៤ រហូតដល់ដំណាច់ឆ្នាំ ២០២៤។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វាមីលី ក៏បានសហការជាមួយអតិថិជនរបស់យើងដើម្បីរៀបចំឡើងវិញនៃឥណទាន និងផ្តល់ការគាំទ្រដល់អ្នកដែលប្រឈមនឹងការលំបាកផ្នែកហិរញ្ញវត្ថុ។

ឆ្នាំមុន មានការលំបាកជាខ្លាំងសម្រាប់គ្រឹះស្ថានរបស់យើង ដោយសារយើងប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុមិនច្បាស់លាស់ ដែលបណ្តាលឱ្យយើងខាតបង់ប្រាក់ចំណេញ ។ ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោកដែលកំពុងបន្ត រួមផ្សំជាមួយនឹងផលប៉ះពាល់ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩ និងបរិយាកាសនៃការផ្តល់ប្រាក់កម្ចីដ៏លំបាក បានធ្វើឱ្យអ្នកខ្ចីជាច្រើនមានការលំបាកក្នុងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរបស់ពួកគេ។ ទោះបីជាយើងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក៏ដោយ ក៏យើងមិនអាចដោះស្រាយបានទាំងស្រុងនូវបញ្ហាប្រឈមទាំងនេះដែរ។ ទោះយ៉ាងណាក៏ដោយ យើងនៅតែរក្សាគោលំហរ និងទំនួលខុសត្រូវរបស់យើងចំពោះស្ថានភាពបច្ចុប្បន្ន។ យើងនឹងធ្វើការយ៉ាងសកម្មដើម្បីពិនិត្យមើលការអនុវត្តន៍ការផ្តល់ប្រាក់កម្ចី កែលម្អយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ពង្រឹងដើមទុន និងលើកកម្ពស់និរន្តរភាពហិរញ្ញវត្ថុរបស់យើង។ ការផ្តោតសំខាន់របស់យើងគឺ ផ្តោតទៅលើការជួយដល់ប្រជាជនដែលខ្វះខាតក្នុងប្រទេសកម្ពុជា ហើយយើងប្តេជ្ញាធានាថា យើងនឹងផ្តល់សេវាកម្មយ៉ាងល្អដល់ប្រជាជន និងជួយប្រជាជនខ្មែរឲ្យមានជីវភាពធូរធារ។

ខណៈពេលដែលឆ្នាំនេះបាននាំមកនូវបញ្ហាប្រឈមសំខាន់ៗមួយចំនួន យើងមានទំនុកចិត្តថាវិធានការទាំងនេះ រួមជាមួយនឹងការខិតខំប្រឹងប្រែងរបស់ក្រុមការងារ និងភាគីដែលពាក់ព័ន្ធ នឹងអាចឱ្យយើងឆ្លងផុតពីភាពលំបាកផ្នែកហិរញ្ញវត្ថុបច្ចុប្បន្ន។ យើងប្តេជ្ញាកែលំអស្ថានភាពឲ្យបានល្អប្រសើរឡើងវិញ និងបន្តបំពេញបេសកកម្មរបស់យើងក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកហរិញ្ញវត្ថុដល់ប្រជាជន លើកស្ទួយជីវភាព និងសេដ្ឋកិច្ចជាតិ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការបន្តគាំទ្ររបស់ម្ចាស់ភាគហ៊ុន បុគ្គលិក និងអតិថិជនរបស់យើងក្នុងអំឡុងពេលដ៏លំបាកនេះ។ ការអត់ធ្មត់ និងការយោគយល់របស់អ្នកគឺមានតម្លៃមិនអាចកាត់ថ្លៃបាន។

យើងនឹងខិតខំប្រឹងប្រែងដើម្បីផ្លាស់ប្តូរមុខមាត់ក្រុមហ៊ុនរបស់យើង និងធ្វើឲ្យក្រុមហ៊ុនរបស់យើងមានការរីកចម្រើនប្រកបដោយនិរន្តរភាព នាពេលអនាគត។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់

ហត្ថលេខា

**លោក វូ ចិន**

**ប្រធានក្រុមប្រឹក្សាភិបាល**

# II. ការគ្រប់គ្រងប្រតិបត្តិការ និងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន

## ១. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន និងគណៈគ្រប់គ្រង



## ❖ គណៈកម្មាធិការវិន័យ

ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានបានអនុម័តបង្កើត នូវគណៈកម្មាធិការវិន័យ សម្រាប់ការវិនិច្ឆ័យ ស៊ើបអង្កេត នៅពេលចាំបាច់របស់សមាជិកណាមួយ ដែលត្រូវបានរកឃើញថាបំពានលើក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុង និងគោលការណ៍។ គណៈកម្មាធិការត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យ និងបណ្តឹងតវ៉ា ឬបញ្ហាដែលទាក់ទងនឹងបុគ្គលិក និងដើម្បីពិភាក្សាលម្អិតក្នុងចំណោមសមាជិកទាំងអស់ ម្យ៉ាងវិញទៀត ដើម្បីធានាថាក្រមសីលធម៌ តួនាទី និងបទបញ្ញត្តិត្រូវបានដឹងច្បាស់ដោយបុគ្គលិកគ្រប់ៗរូប។

### កិច្ចប្រជុំ:

ការប្រជុំនៃគណៈកម្មាធិការត្រូវធ្វើឡើងយ៉ាងហោចណាស់ឱ្យបាន២ដងក្នុងមួយឆ្នាំ។
ប្រធាននៃគណៈកម្មាធិការ អាចកោះប្រជុំបន្ថែមប្រសិនបើចាំបាច់។

### សមាជិកភាព:

សមាជិកគណៈកម្មាធិការវិន័យរួមមានដូចខាងក្រោម:

- អគ្គនាយក : ប្រធាន
- ប្រធានធនធានមនុស្ស និងរដ្ឋបាល : សមាជិក
- ប្រធានហិរញ្ញវត្ថុ : សមាជិក

## ❖ គណៈកម្មាធិការឥណទាន

ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានបានអនុម័តបង្កើត នូវគណៈកម្មាធិការឥណទាន ដើម្បីធានាបាននូវការអនុលោមតាមបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា និងពង្រឹងគុណភាពប្រាក់កម្ចី។ គោលបំណងនៃគណៈកម្មាធិការនេះ គឺដើម្បីត្រួតពិនិត្យ ដោះស្រាយ អនុម័តឥណទាន និងរៀបចំនីតិវិធី គោលការណ៍។ លើសពីនេះទៀត គណៈកម្មាធិការនេះនឹងត្រួតពិនិត្យក្របខណ្ឌ នៃការគ្រប់គ្រងហានិភ័យឥណទានទាក់ទងនឹងអាជីវកម្មរបស់ស្ថាប័នទាំងមូល។

### កិច្ចប្រជុំ:

ការប្រជុំនៃគណៈកម្មាធិការត្រូវធ្វើឡើងយ៉ាងហោចណាស់ឱ្យបាន១ដងក្នុងមួយខែ។ ប្រធាននៃគណៈកម្មាធិការ អាចកោះប្រជុំបន្ថែមប្រសិនបើចាំបាច់។

### សមាជិកភាព:

សមាជិកគណៈកម្មាធិការឥណទានរួមមានដូចខាងក្រោម:

- អគ្គនាយក : ប្រធាន
- ប្រធានឥណទាន : សមាជិក
- ប្រធានហិរញ្ញវត្ថុ : សមាជិក

## ❖ គណៈកម្មាធិការថ្នាក់គ្រប់គ្រង

ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន បានបង្កើតនូវគណៈកម្មការមួយដែលមានឈ្មោះថា គណៈកម្មា-ធិការថ្នាក់គ្រប់គ្រង គឺដើម្បីពិភាក្សារាល់បញ្ហាប្រឈមទាំងឡាយណារបស់ក្រុមហ៊ុន និងស្វែងរកដំណោះស្រាយ ដើម្បីធ្វើឱ្យប្រាកដថាប្រតិបត្តិការរបស់ក្រុមហ៊ុនដំណើរការដោយរលូន។ បន្ថែមលើនេះគណៈកម្មាធិការថ្នាក់គ្រប់គ្រង ក៏ត្រូវធ្វើការត្រួតពិនិត្យ និងឃ្លាំមើលការខុសត្រូវ លើការអភិវឌ្ឍន៍ និងការអនុវត្តន៍កែលម្អផែនការអាជីវកម្ម និងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន ដើម្បីពិភាក្សាអំពីនិន្នាការទីផ្សារ និងការប្រកួតប្រជែងនាពេលបច្ចុប្បន្ន យុទ្ធសាស្ត្រទីផ្សារ ដើម្បីបង្កើតឱកាសអាជីវកម្មថ្មីៗ និងផ្តល់យោបល់ទៅដល់ក្រុមប្រឹក្សាភិបាល ដើម្បីបំពេញតាមចក្ខុវិស័យ និងគោលបំណងរបស់ក្រុមហ៊ុនឱ្យបានជោគជ័យ។

### កិច្ចប្រជុំ

ក. គណៈកម្មាធិការថ្នាក់គ្រប់គ្រងនឹងរៀបចំកិច្ចប្រជុំជាប្រចាំខែ។ ប្រធានគណៈកម្មាធិការ ឬសមាជិកភាគច្រើន នៃ គណៈកម្មាធិការអាចកោះប្រជុំពិសេសរបស់ខ្លួននៅក្នុងប្រជុំគណៈកម្មាធិការថ្នាក់គ្រប់គ្រងបាន។

ខ. សមាជិកភាគច្រើននៃគណៈកម្មាធិការថ្នាក់គ្រប់គ្រង ដែលមានវត្តមានដោយផ្ទាល់ ឬតាមរយៈមធ្យោបាយទំនាក់ទំនងផ្សេងៗទៀត តាមគ្រប់មធ្យោបាយនៃកិច្ចប្រជុំតាមប្រព័ន្ធអនឡាញដែលអាចធ្វើការទំនាក់ទំនងគ្នាទៅវិញទៅមកបាន អាចបង្កើតជាកូរ៉ុមក្រុមបាន។ សេចក្តីសម្រេចរបស់សមាជិកភាគច្រើនដែលមានវត្តមាននៅក្នុងកិច្ចប្រជុំដែលមានវត្តមាន និងត្រូវបានង្កើតជាកូរ៉ុមក្នុងក្រុម គឺជាសេចក្តីសម្រេចរួមរបស់គណៈកម្មាធិការ។
ជំនួសមុខឱ្យការប្រជុំ គណៈកម្មាធិការអាចចាត់វិធានការណាមួយដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរ និង/ឬជាឯកច្ឆ័ន្ទ។

### សមាជិកភាព:

សមាសភាពរបស់គណកម្មាធិការថ្នាក់គ្រប់គ្រងរួមមានដូចខាងក្រោម៖

- អគ្គនាយក : ប្រធាន
- ប្រធានប្រតិបត្តិតាម : សមាជិក
- ប្រធានឥណទាន : សមាជិក
- ប្រធានហិរញ្ញវត្ថុ : សមាជិក
- ប្រធានធនមនុស្សនិងរដ្ឋបាល : សមាជិក
- ប្រធានព័ត៌មានវិទ្យា : សមាជិក

## ❖ គណៈកម្មាធិការគ្រប់គ្រងបណ្តឹងតវ៉ា

ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន បានអនុម័តបង្កើតគណៈកម្មាធិការគ្រប់គ្រងបណ្តឹងតវ៉ា ដើម្បីធានាឱ្យបាននូវការអនុលោមតាមកម្មវិធីរបស់ធនាគារជាតិ នៃកម្ពុជា និងអនុវត្តក្របខណ្ឌគ្រប់គ្រងបណ្តឹងតវ៉ារបស់អតិថិជន។ គោលបំណងនៃការបង្កើតគណៈកម្មាធិការនេះ គឺដើម្បីដោះស្រាយបណ្តឹងតវ៉ារបស់អតិថិជនក្រោមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ស្តីអំពីដំណោះស្រាយបណ្តឹងតវ៉ារបស់ អតិថិជនដែលប្រើប្រាស់សេវាកម្ម អ្នកប្រើប្រាស់ប្រាក់កម្ចី និងយុន្តការគ្រប់គ្រង បណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់ (CCMF )។ លើសពីនេះ គណៈកម្មាធិការ ត្រូវត្រួតពិនិត្យទៅលើក្របខ័ណ្ឌនៃការគ្រប់គ្រងបណ្តឹងតវ៉ារបស់អតិថិជនទាក់ទងនឹងអាជីវកម្មរបស់ស្ថាប័នទាំងមូល។

### កិច្ចប្រជុំ

ការប្រជុំជាផ្លូវការដែលមានថៃងក្នុងកាតព្វកិច្ចដែលបានកំណត់ខាងក្រោមត្រូវធ្វើឡើងចំនួន៤ដង ក្នុងមួយឆ្នាំ។ប្រធានគណៈកម្មាធិការគ្រប់គ្រងបណ្តឹងតវ៉ា អាចកោះប្រជុំបន្ថែមប្រសិនបើចាំបាច់។

### សមាជិកភាព

សមាជិកគណៈកម្មាធិការទាំងនេះរួមមានដូចខាងក្រោម៖

- អគ្គនាយក : ប្រធាន
- ប្រធានហិរញ្ញវត្ថុ : សមាជិក
- ប្រធានធនធានមនុស្ស និងរដ្ឋបាល : សមាជិក
- ប្រធានឥណទាន : សមាជិក
- ប្រធានប្រតិបត្តិតាម : សមាជិក

## ❖ គណៈកម្មាធិការព័ត៌មានវិទ្យា

គណៈកម្មាធិការព័ត៌មានវិទ្យាក្រុមប្រឹក្សា(ITC) ត្រូវបានដឹកនាំដោយនាយកប្រតិបត្តិ(CEO) ហើយដែលត្រូវបានបង្កើតឡើងដើម្បីជំនួយដល់ការគ្រប់គ្រងប្រតិបត្តិការ ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រព័ត៌មានវិទ្យា( IT) ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ វាត្រូវបានផ្តល់អាទិភាពលើការវិនិយោគដោយបើកឲ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីតាមដាននិងត្រួតពិនិត្យមើលស្ថានភាពនៃគម្រោងឬផែនការទាំងឡាយរបស់ស្ថាប័ន (វាត្រូវបានរួមបញ្ចូលទាំង resource conflict) ការត្រួតពិនិត្យកម្រិតនៃសេវាកម្ម និងការកែលម្អប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការផ្តល់សេវាបច្ចេកវិទ្យាព័ត៌មានទៅដល់ប្រតិបត្តិការអាជីវកម្ម និងគម្រោងផ្សេងៗដែលពាក់ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

## កិច្ចប្រជុំ

កិច្ចប្រជុំផ្លូវការផ្តែកលើបញ្ហាផ្សេងៗដែលមានចែងក្នុងភារកិច្ចដែលបានកំណត់ខាងលើត្រូវធ្វើឡើងចំនួន២ដងក្នុងមួយឆ្នាំ។ ប្រធានគណៈកម្មាធិការព័ត៌មានវិទ្យាអាចកោះប្រជុំបន្ថែមប្រសិនបើចាំបាច់។

## សមាជិកភាព:

សមាជិកគណៈកម្មាធិការទាំងនេះរួមមានដូចខាងក្រោម៖

- អគ្គនាយក : ប្រធាន
- ប្រធានព័ត៌មានវិទ្យា : សមាជិក
- ប្រធានឥណទាន : សមាជិក
- ប្រធានប្រតិបត្តិតាម : សមាជិក
- ប្រធានហិរញ្ញវត្ថុ : សមាជិក

# ២. គណៈគ្រប់គ្រង



**លោក កាំង លាងប៉ោ**

អគ្គនាយក

**លោក កាំង លាងប៉ោ** ជានាយកប្រតិបត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ចាប់តាំងពីឆ្នាំ២០១៩។ លោកមានបទពិសោធន៍ជាង១០ឆ្នាំ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ហើយលោកធ្លាប់បានបម្រើការងារក្នុងនាមជាថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ផ្សេងៗគ្នាជាច្រើនក្នុងបទពិសោធន៍ជំនាញរបស់លោក ដូចជាការគ្រប់គ្រងអាជីវកម្ម ប្រតិបត្តិការ ហិរញ្ញវត្ថុ និងទីផ្សារមូលបត្រ។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ ធនាគារ និងធានារ៉ាប់រង នៅឆ្នាំ ២០១៥ ពីសាកលវិទ្យាល័យ Nantes នៃ ប្រទេសបារាំង។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ នៅឆ្នាំ ២០១១ ពីវិទ្យាស្ថាន វ៉ាន់ដា និងថ្នាក់បរិញ្ញាបត្ររងផ្នែកធនាគារ នៅឆ្នាំ ២០១១ ពីមជ្ឈមណ្ឌលសិក្សាផ្នែកធនាគារ ម្យ៉ាងវិញទៀតលោកក៏បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅឆ្នាំ២០១២ ពីសាកលវិទ្យាល័យកម្ពុជា។ មុនពេលផ្លាស់ប្តូរចូលក្នុង/មកវិស័យធនាគារលោកក៏ធ្លាប់មានបទពិសោធន៍ការងារ៥ឆ្នាំ នៅក្នុងផ្នែកទីផ្សារហិរញ្ញវត្ថុកម្ពុជា ដោយ **លោក កាំង លាងប៉ោ** មានតួនាទីជាអ្នកដឹកនាំសំខាន់ៗ ជាច្រើនរួមមាន ប្រធានផ្នែកលក់ និងប្រធានផ្នែកទីផ្សារ ប្រធានផ្នែកប្រតិបត្តិការ និងជា អនុប្រធាននាយកប្រតិបត្តិនៅក្រុមហ៊ុនកាណា ស៊ីឃ្យូរីធី អិលធីឌី ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ កាណាឌីយ៉ា ក.អ។ លោកធ្លាប់ជាប្រធានប្រតិបត្តិការដែលមានអាជ្ញាប័ណ្ណទទួលស្គាល់ដោយគណៈកម្មការមូលបត្រកម្ពុជា។
បច្ចុប្បន្នលោកជាអគ្គនាយក នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម ក.។



**លោកហង់ បូរាណ**

អគ្គនាយករង និងប្រធានហិរញ្ញវត្ថុ

**លោក ហង់ បូរាណ** បានបញ្ចប់សញ្ញាបត្រផ្នែកស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិសម្រាប់សហគ្រាសធុនតូច និងមធ្យម (IFRS-SMEs) នៅសាលា CamEd Business School ក្នុងឆ្នាំ ២០២២។ លោកក៏បានបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យ ជាស៊ីម កំចាយមារ (CSUK) ក្នុងឆ្នាំ ២០០៩។ ទាក់ទងនឹងបទពិសោធន៍ការងារ លោកធ្លាប់បានបម្រើការងារជាមន្ត្រីគណនេយ្យ នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី គាត់បានធ្វើការជា មន្ត្រីជាន់ខ្ពស់ផ្នែកគណនេយ្យ និងមន្ត្រីរដ្ឋបាល នៅប្រតិបត្តិករឥណទានជនបទសុវណ្ណភូមិ ហើយក៏ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេផល ភីអិលស៊ី (បច្ចុប្បន្នបានប្តូរទៅជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាន់នី ភីអិលស៊ី) ម្យ៉ាងវិញទៀត លោក **ហង់ បូរាណ ធ្លាប់មានតួនាទី** ជាប្រធានហិរញ្ញវត្ថុនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធី & ហ្គូរ ភីអិលស៊ី និងក៏ធ្លាប់បម្រើការងារជាអ្នកប្រធានគ្រប់គ្រងហិរញ្ញវត្ថុ នៅធនាគារហុងលីអុង (ខេមបូឌា)។

បច្ចុប្បន្ន **លោក ហង់ បូរាណ** បាន និងកំពុងបម្រើការងារ នៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ក្នុងមុខតំណែង ជាអគ្គនាយករង ហើយលោកក៏កាន់តួនាទីជាប្រធានគ្រប់គ្រងហិរញ្ញវត្ថុ។ ដូច្នេះគាត់បានឆ្លងកាត់បទពិសោធខាងផ្នែកធនាគារ និងហិរញ្ញវត្ថុអស់រយៈពេល១៦ឆ្នាំ ក្នុងនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ដែលទទួលខុសត្រូវចម្បងៗ រួមមាន ការគ្រប់គ្រងទូទៅ តួនាទីជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុគណនេយ្យ គ្រប់គ្រងរតនាគារ តួនាទីរៀបចំផែនការថវិកា តួនាទីគ្រប់គ្រងសាច់ប្រាក់ តួនាទីប្រកាសពន្ធ និងរៀបចំរបាយការណ៍ទាំងអស់ទៅធនាគារជាតិនៃកម្ពុជា។



**លោក រ៉ន រិត**

ប្រធានព័ត៌មានវិទ្យា

**លោក រ៉ន រិត** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រក្នុងឆ្នាំ២០១៧ និងបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រក្នុងឆ្នាំ២០២២ ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ជាមួយនឹងអតីតភាពការងារជិត១០ឆ្នាំរបស់លោក ដូច្នេះ លោកទទួលបានបទពិសោធន៍ជាច្រើន ក្នុងវិស័យ ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលទទួលខុសត្រូវលើផ្នែកប្រព័ន្ធស្នូលរបស់ ធនាគារ បណ្តាញ បច្ចេកវិទ្យាជាមួយនឹងមុខជំនាញបច្ចេកទេសជាច្រើនដូចជា ការគ្រប់គ្រងដំណើរការប្រព័ន្ធស្នូលធនាគារ និងការគ្រប់គ្រងលើបណ្តាញហេដ្ឋារចនាសម្ព័ន្ធបណ្តាញរបស់ធនាគារ ប្រកបដោយសុវត្ថិភាព ការគ្រប់គ្រងគោលនយោបាយព័ត៌មានវិទ្យា និងគ្រប់គ្រងលើការអភិវឌ្ឍន៍ប្រព័ន្ធកម្មវិធីផ្សេងៗ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន រួមទាំង **Hard skills and Soft skills** និងបានផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក អំពីគោលនយោបាយទាក់ទងនឹងប្រព័ន្ធព័ត៌មានវិទ្យា។

នៅចុងឆ្នាំ២០២៣ គាត់បានចូលបម្រើការងារជាមួយ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី** ម.ក ដែលមានតួនាទី ជាប្រធានព័ត៌មានវិទ្យា ដើម្បីពង្រឹង និង អភិវឌ្ឍបន្ថែមលើការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធនៃបណ្តាញ គ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ ប្រព័ន្ធស្នូលរបស់ធនាគារ គោលការណ៍ព័ត៌មានវិទ្យា សុវត្ថិភាពទិន្នន័យក៏ដូចជាការអនុវត្តន៍គោលការណ៍សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក ដើម្បីធ្វើឱ្យប្រតិបត្តិការកាន់តែល្អប្រសើរឡើង មានសុវត្ថិភាព និងមានភាពស៊ីចង្វាក់ជាងមុន។



**លោកស្រី បួក ស្រីនិច្ច**

ប្រធានស្តីទីធនធានមនុស្ស និងរដ្ឋបាល

**លោកស្រី បួក ស្រីនិច្ច** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ ពីសកលវិទ្យាល័យអាស៊ីអឺរ៉ុប ក្នុងឆ្នាំ២០១៩។ ទាក់ទងនឹងបទពិសោធន៍ការងារ លោកស្រីមានបទពិសោធន៍ជាង៧ឆ្នាំ នៅក្នុងវិស័យហិរញ្ញវត្ថុ មុននឹងចូលរួមជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី លោកស្រីបានធ្វើជាបេឡាករ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខ្មែរតា ហើយធ្លាប់ធ្វើការនៅ អេស៊ា ផេស៊ីហ្វិក ហ្វាយនែន (បច្ចុប្បន្នគឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គង្គា យែភីចល) ធ្លាប់ធ្វើការជាបេឡាករជាន់ខ្ពស់នៅ សាយ ហូសចល ម៉ាយក្រូហ្វាយនែន។ នៅដើមឆ្នាំ ២០២៣ លោកស្រីបានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក ក្នុងមុខតំណែងជាប្រធានបេឡាករ បន្ទាប់មកលោកស្រីត្រូវបានតែងតាំងទៅ ជាប្រធានស្តីទីធនធានមនុស្ស និងរដ្ឋបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក ។



**លោក រ៉េម សំអុល**

ប្រធានឥណទាន

**លោក រ៉េម សំអុល** គឺជាប្រធានឥណទាននៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក ដែលលោកបាននាំមកនូវបទពិសោធន៍ ចំណេះជំនាញ រយៈពេល៧ឆ្នាំក្នុង វិស័យធនាគារ និងហិរញ្ញវត្ថុនៃប្រទេសកម្ពុជា ជាពិសេសក្នុងការគ្រប់គ្រងឥណទាន។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែក គ្រប់គ្រងសណ្ឋាគារ និងទេសចរណ៍ពីសាកលវិទ្យាល័យអាស៊ីអឺរ៉ុប ក្នុងឆ្នាំ២០១៧។ ជាច្រើនឆ្នាំមកនេះ លោកបានបង្កើតនិងបំពេញតួនាទីតាមជំនាញរបស់លោកបានយ៉ាងល្អប្រសើរ ក្នុងការគ្រប់គ្រងឥណទាន ការផ្តល់ប្រាក់កម្ចីជូនអតិថិជន និងការគ្រប់គ្រងប្រាក់កម្ចីឥណទានមិនដំណើរការ (NPL)។ មុនពេលលោកចូលបំពេញការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក លោករ៉េម **សំអុល** បានបំពេញតួនាទីសំខាន់ៗជាច្រើនក្នុងវិស័យឥណទានជាមួយស្ថាប័នហិរញ្ញវត្ថុ រួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន ម.ក ABA និង LEDA Capital Plc។ បច្ចុប្បន្ន លោកទទួលបន្ទុកលើផ្នែកដូចជា ប្រតិបត្តិការឥណទាន ការវាយតម្លៃហានិភ័យឥណទាន ការផ្តល់ប្រាក់កម្ចី និងការគ្រប់គ្រងឥណទានមិនដំណើរការ(NPL) ដោយធានាបាននូវយុទ្ធសាស្ត្រឥណទាន ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពផ្នែកហិរញ្ញវត្ថុសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក។

# ៣. ផលិតផល និងសេវាកម្ម

## ៣.១. ឥណទានអាជីវកម្ម

កម្ចីអាជីវកម្មរបស់យើង ត្រូវបានរចនាឡើងសម្រាប់ពាណិជ្ជករ និងសហគ្រិនទាំងឡាយណាដើម្បីចាប់ផ្តើមអាជីវកម្មថ្មី ឬពង្រីកអាជីវកម្មដែលមានស្រាប់។ គ្រប់សហគ្រាសធុនតូច និងមធ្យម ទាំងអស់អាចទទួលបានកម្ចីប្រភេទនេះសម្រាប់ដើមទុនវិនិយោគ ឬដើមទុនធ្វើការសម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួនជាមួយនឹងការផ្តល់ជូននូវអត្រាការប្រាក់ពិសេស។ ទំហំប្រាក់កម្ចីរបស់យើងមានចាប់ពីកម្ចីខ្នាតតូច រហូតដល់កម្ចីខ្នាតមធ្យមដែលមានចំនួនអតិបរមា១៥០.០០០ដុល្លារ ឬសមមូលរូបិយប័ណ្ណផ្សេង។ អតិថិជនអាចទទួលបានកម្ចីរបស់យើងដើម្បីប្រើប្រាស់សម្រាប់អាជីវកម្មទាន់ពេលវេលាដើម្បី សម្រេចបាននូវគោលដៅរបស់ខ្លួន ជាមួយនឹងឯកសារងាយៗ និងដំណើរការអនុម័តឆាប់រហ័ស។



**លក្ខណៈពិសេសនៃផលិតផល៖**

- រយៈពេលកម្ចីបានរហូតដល់១០ឆ្នាំ
- អត្រាការប្រាក់ទាក់ទាញជាមួយនឹងការបង់សងត្រលប់អាចបត់បែនបាន
- ការរៀបចំឯកសាររហ័សទាន់ចិត្ត មានរយៈពេលត្រឹមតែ២ទៅ៥ថ្ងៃប៉ុណ្ណោះ
- លក្ខខណ្ឌងាយៗ។

**ឯកសារតម្រូវ៖**

- ទទួលយកទាំងប្លង់រឹង និងប្លង់ទន់
- អត្តសញ្ញាណប័ណ្ណនិងឯកសារបញ្ជាក់អត្តសញ្ញាណបុគ្គល
- លិខិតបញ្ជាក់ការងារ ឬឯកសារចំណូលអាជីវកម្ម។

## ៣.២. ឥណទានគេហដ្ឋាន

ភាពជាម្ចាស់នៃលំនៅដ្ឋានមួយ គឺជាក្ដីស្រមៃរបស់មនុស្សគ្រប់រូប។ ជាមួយគ្នានោះដែរគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក យើងអាចធ្វើឱ្យលំនៅដ្ឋានក្នុងក្ដីស្រមៃរបស់អស់លោកអ្នកក្លាយជាការពិតបានគ្រប់ពេលវេលា។ លោកអ្នកអាចខ្ចីប្រាក់បានរហូតដល់៨០ %នៃតម្លៃផ្ទះ សម្រាប់រយៈពេល ២០ឆ្នាំ ជាមួយអត្រាការប្រាក់មួយដ៏គួរឱ្យទាក់ទាញ។ **ឧទាហរណ៍** បើលោកអ្នកមានបំណងចង់ទិញលំនៅដ្ឋានមួយ ក្នុងតម្លៃចំនួន១០០.០០០ដុល្លារ ដោយលោកអ្នកគ្រាន់តែមានប្រាក់ចូលរួមចំនួន២០.០០០ដុល្លារនោះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក នឹងផ្ដល់ប្រាក់កម្ចីជូនលោកអ្នកចំនួន៨០.០០០ដុល្លារ សម្រាប់រយៈពេល២០ឆ្នាំ ជាមួយនឹងអត្រាការប្រាក់ដ៏សមរម្យ។



**លក្ខណៈពិសេសនៃផលិតផល៖**

- ទំហំឥណទានចាប់ពី១០.០០០ដុល្លារ ដល់ ១៥០.០០០ដុល្លារ
- រយៈពេលកម្ចីបានរហូតដល់២០ឆ្នាំ
- អត្រាការប្រាក់ទាក់ទាញជាមួយនឹងការបង់សងត្រលប់អាចបត់បែនបាន
- ការរៀបចំឯកសាររហ័សទាន់ចិត្ត មានរយៈពេលត្រឹមតែ២ទៅ ៥ថ្ងៃប៉ុណ្ណោះ
- លក្ខខណ្ឌងាយៗ។

**ឯកសារតម្រូវ៖**

- ទទួលយកទាំងប្លង់រឹង និងប្លង់ទន់
- អត្តសញ្ញាណប័ណ្ណ និងឯកសារបញ្ជាក់អត្តសញ្ញាណបុគ្គល
- កិច្ចសន្យាការងារ ឬឯកសារប្រាក់ចំណូលអាជីវកម្មផ្សេងៗ។

## ៣.៣. ឥណទានរថយន្ត

ធ្វើឱ្យក្តីស្រមៃរបស់លោកអ្នកក្លាយជាការពិត ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ដោយផ្តល់ជូនអតិថិជន នូវមធ្យោបាយសាមញ្ញ និងភាពងាយស្រួល ក្នុងការក្លាយជាម្ចាស់រថយន្តដែលពួកគេប្រាថ្នា ជាមួយនឹងការទូទាត់ប្រាក់ប្រចាំខែដ៏សមរម្យមួយ និងដោយមិនចាំបាច់មានទ្រព្យធានា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី បានសហការជាមួយយានដ្ឋានរថយន្តជាច្រើន ដើម្បីផ្តល់ ជម្រើសងាយស្រួល និងដំណើរការលឿនជាងមុនសម្រាប់ជូនដល់អតិថិជនក្នុងការទទួលបានប្រាក់កម្ចីសម្រាប់ទិញរថយន្តជាមួយនឹងដៃគូយានដ្ឋានរបស់យើង។



**លក្ខណៈពិសេសនៃផលិតផលៈ**

- ទំហំឥណទានចាប់ពី១.០០០ដុល្លារ ដល់ ៥០.០០០ដុល្លារ
- រយៈពេលកម្ចីបានរហូតដល់៥ឆ្នាំ
- អត្រាការប្រាក់ទាក់ទាញជាមួយនឹងការបង់សងត្រលប់អាចបត់បែនបាន
- ការរៀបចំឯកសាររហ័សទាន់ចិត្ត មានរយៈពេលត្រឹមតែ១ទៅ៣ថ្ងៃប៉ុណ្ណោះ
- លក្ខខណ្ឌងាយៗ
- មិនតម្រូវឲ្យមានទ្រព្យបញ្ចាំ។

**ឯកសារតម្រូវៈ**

- អត្តសញ្ញាណប័ណ្ណ និងឯកសារបញ្ជាក់អត្តសញ្ញាណបុគ្គល
- កិច្ចសន្យាការងារ ឬឯកសារប្រាក់ចំណូលអាជីវកម្មផ្សេងៗ
- មានអ្នកធានា។

## ៣.៤. ឥណទានទោចក្រយានយន្ត និងកង់បី

ការធ្វើដំណើរតាមរ៉ឺម៉ក ឬម៉ូតូមានការកើនឡើងជារៀងរាល់ថ្ងៃ។ ជាមួយឥណទានទិញម៉ូតូ ឬ រ៉ឺម៉ក កង់បី របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី អតិថិជនអាចទទួលបាននូវលក្ខខណ្ឌងាយៗក្នុងការទទួលបានម៉ូតូ សម្រាប់ធ្វើដំណើរទៅបម្រើការងារ ឬទិញរ៉ឺម៉ក កង់បី សម្រាប់ប្រកបអាជីវកម្មផ្សេងៗ ដើម្បីរកប្រាក់ចំណូលប្រចាំថ្ងៃ។




**លក្ខណៈពិសេសនៃផលិតផល៖**

- ទំហំឥណទានចាប់ពី១.០០០ដុល្លារ ដល់៦.០០០ដុល្លារ
- រយៈពេលកម្ចីបានរហូតដល់៣ឆ្នាំ
- អត្រាការប្រាក់ទាក់ទាញជាមួយនឹងការបង់សងត្រលប់អាចបត់បែនបាន
- ការរៀបចំឯកសាររហ័សទាន់ចិត្ត មានរយៈពេលត្រឹមតែ១ថ្ងៃប៉ុណ្ណោះ
- លក្ខខណ្ឌងាយៗ
- មិនតម្រូវឲ្យមានទ្រព្យបញ្ចាំ។

**ឯកសារតម្រូវ៖**

- អត្តសញ្ញាណប័ណ្ណ និងឯកសារបញ្ជាក់អត្តសញ្ញាណបុគ្គល
- កិច្ចសន្យាការងារ ឬឯកសារប្រាក់ចំណូលអាជីវកម្មផ្សេងៗ
- មានអ្នកធានា។

## ៣.៥. ឥណទានផ្ទាល់ខ្លួន

ប្រាក់កម្ចីផ្ទាល់ខ្លួន ផ្តល់នូវប្រភពហិរញ្ញប្បទានដល់បុគ្គលម្នាក់ៗ ដើម្បីទិញទំនិញប្រើប្រាស់ក្នុងផ្ទះ ដូចជា សម្ភារៈគ្រឿងសង្ហារឹម ដើម្បីសោភ័ណភាពផ្ទះ ឬតម្រូវការចាំបាច់ក្នុងការរស់នៅប្រចាំថ្ងៃ (ឧទាហរណ៍៖ សម្ភារៈតុបតែងហាងកែសម្ផស្ស ឬ ម៉ាស៊ីនត្រជាក់ ជាដើម ល)ដោយមិនចាំបាច់តម្រូវអោយមានទ្រព្យដាក់ធានាឡើយ អតិថិជនក៏អាចទទួលបាននូវលក្ខខណ្ឌងាយស្រួល ក្នុងការទទួលបានប្រាក់កម្ចី ក្នុងគោលបំណងសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ដើម្បីធ្វើឱ្យជីវភាព និងជីវិតរបស់ពួកគេកាន់តែប្រសើរឡើង។



**លក្ខណៈពិសេសនៃផលិតផល៖**

- ទំហំឥណទានចាប់ពី៥០០ដុល្លារ ដល់២.០០០ដុល្លារ
- រយៈពេលកម្ចីបានរហូតដល់២ឆ្នាំ
- អត្រាការប្រាក់ទាក់ទាញជាមួយនឹងការបង់សងត្រលប់អាចបត់បែនបាន
- ការរៀបចំឯកសាររហ័សទាន់ចិត្ត មានរយៈពេលត្រឹមតែ១ទៅ២ថ្ងៃប៉ុណ្ណោះ
- លក្ខខណ្ឌងាយៗ
- មិនតម្រូវមានទ្រព្យបញ្ចាំ។

**ឯកសារតម្រូវ៖**

- អត្តសញ្ញាណប័ណ្ណ និងឯកសារបញ្ជាក់អត្តសញ្ញាណបុគ្គល
- កិច្ចសន្យាការងារ ឬឯកសារប្រាក់ចំណូលអាជីវកម្មផ្សេងៗ
- មានអ្នកធានា។

## ៣.៦. ឥណទានកសិកម្ម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ផ្តល់ប្រាក់កម្ចីដល់កសិករ និងអតិថិជនទាំងឡាយណាដែលមានមុខរបរផ្ទាល់ខ្លួនដ៏ទៃផ្សេងៗទៀតទាក់ទងទៅនឹងវិស័យកសិកម្ម។ ឥណទានកសិកម្ម អាចត្រូវបានប្រើដើម្បីទិញគ្រឿងចក្រ និងឧបករណ៍ដែលបម្រើក្នុងវិស័យកសិកម្ម ដូចជា ជី ថ្នាំសង្កូវ និងគ្រាប់ពូជ បសុសត្វ និងរបស់របរ ស្រដៀងគ្នាផ្សេងទៀត។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ផ្តល់នូវលក្ខខណ្ឌទូទាត់ប្រាក់សងត្រឡប់ដែលអាចបត់បែនបានតាមរដូវកាល និងងាយស្រួល ស្របតាមស្ថានភាពមុខរបររបស់កសិករដើម្បីគាំទ្រ និងធ្វើឱ្យជីវភាពកាន់តែប្រសើរឡើង។



**លក្ខណៈពិសេសនៃផលិតផលៈ**

- ទំហំឥណទានចាប់ពី១.០០០ដុល្លារ ដល់១០០.០០០ដុល្លារ
- រយៈពេលកម្ចីបានរហូតដល់១០ឆ្នាំ
- អត្រាការប្រាក់ទាក់ទាញជាមួយនឹងការបង់សងត្រលប់អាចបត់បែនបាន
- ការរៀបចំឯកសាររហ័សទាន់ចិត្ត មានរយៈពេលត្រឹមតែ២ទៅ៥ថ្ងៃប៉ុណ្ណោះ
- លក្ខខណ្ឌងាយៗ។

**ឯកសារតម្រូវៈ**

- ទទួលយកទាំងប្លង់រឹង និងប្លង់ទន់
- អត្តសញ្ញាណប័ណ្ណ និងឯកសារបញ្ជាក់អត្តសញ្ញាណបុគ្គល
- កិច្ចសន្យាការងារ ឬឯកសារប្រាក់ចំណូលអាជីវកម្មផ្សេង។

# ៤. សកម្មភាពសង្គមរបស់ក្រុមហ៊ុន

## ❖ ព្រឹត្តិការណ៍កីឡា

ការលេងកីឡាបាល់ទាត់ ដើម្បីសុខភាពល្អរឹងមាំ និង ដើម្បីបង្កើតស្មារតីសាមគ្គីភាពជាមួយក្រុម ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វាមីលី កីឡាជំរុញឲ្យមានភាពក្លាហាន មានភាពឆ្លាតវៃ មានភាពរហ័សរហួន មានភាពជាអ្នកដឹកនាំ និងសុខុមាលភាពផ្លូវកាយ និងផ្លូវចិត្តទាំងមូល ដែលជាគុណសម្បត្តិ ឬគុណតម្លៃ ចាំបាច់បំផុត ទាំងក្នុងជីវិត និងកន្លែងការងារ។

ដោយមានការទទួលស្គាល់អំពីអត្ថប្រយោជន៍ជាច្រើននៃការលេងកីឡា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វាមីលីបានរៀបចំឡើងនូវកម្មវិធីបាល់ទាត់រៀងរាល់មួយខែម្តងសម្រាប់បុគ្គលិកគ្រប់បុគ្គលិកគ្រប់ៗរូប។ ក្រៅពីការលើកកម្ពស់កាយសម្បទា និងសុខុមាលភាពនៃសរសៃឈាមក្នុងបេះដូងឲ្យមានដំណើរការល្អប៉ុណ្ណោះទេ តែការលេងកីឡាបាល់ទាត់វាក៏ជួយធ្វើឱ្យប្រព័ន្ធមុខងារផ្លូវដង្ហើមមានដំណើរការកាន់តែល្អប្រសើរឡើង កាត់បន្ថយការឡើងគីឡូ ជួយបង្កើតអោយមានកម្លាំងសាច់ដុំរឹងមាំ និងជំរុញអោយមានការហកការល្អជាក្រុម ជាពិសេសកីឡាក៏ជួយរឹតចំណងមិត្តភាពឲ្យមានភាពស្និទ្ធស្នាលក្នុងចំណោមមិត្តភក្តិរួមការងារថែមទៀតផង។

ទោះបីជាការប្រកួតកីឡាបាល់ទាត់មានរយៈពេលរហូតដល់ទៅ ពីរម៉ោងហើយបានធ្វើឱ្យកីឡាករ កីឡាការិនីមានសភាពអស់កម្លាំងនិងហត់នឿយលើផ្នែករាងកាយក៏ដោយ តែភាពរំភើប ក៏ដូចជាភាពសប្បាយរីករាយ រួមជាមួយនិងស្មារតីសហការជាក្រុមបានល្អ នោះបានធ្វើឱ្យវាក្លាយជាបទពិសោធន៍ដ៏រីករាយមួយ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វាមីលី ជឿជាក់យ៉ាងមុតមាំថាការបញ្ចេញកម្លាំងពលកម្មដែលប្រកបដោយសុខុមាលភាពល្អ រមៀងនាំយើងឆ្ពោះទៅរកផលិតភាពកាន់តែច្រើនជាងនេះ ប្រកបដោយប្រសិទ្ធភាព និងធ្វើឲ្យការបំពេញការងារទាំងមូលប្រកបដោយផ្លែផ្កា និងការពេញចិត្ត។







## ❖ សប្បុរសធម៌នៅមណ្ឌលកុមារកំព្រា ព្រៃជ្រុំខេត្តកំពង់ស្ពឺ

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វាមីលី សូមធ្វើការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការជួយជ្រោមជ្រែងក៏ដូចជាការជួយឧបត្ថម្ភដល់សហគមន៍**

គណៈគ្រប់គ្រងនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី បានធ្វើកម្មវិធីសប្បុរសធម៌ទៅកាន់មណ្ឌលកុមារកំព្រា ព្រៃជ្រុំ ដែលស្ថិតនៅ ភូមិព្រៃជ្រុំ ឃុំយុទ្ធសាមគ្គី ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ។ ដោយមើលឃើញពីការលំបាក និងដោយក្តីអាណិត ស្រឡាញ់ចំពោះកុមារទាំងអស់ ដែលមកស្នាក់នៅក្នុងមណ្ឌលកុមារកំព្រាមួយនេះ ពួកយើងបានចូលរួមផ្តល់ជាចំណែកក្នុងការឧបត្ថម្ភនូវសម្ភារៈសិក្សា និងគ្រឿងឧបភោគ បរិភោគមួយចំនួនដើម្បីផ្តល់ជូនទៅឲ្យកុមារកំព្រាចំនួន ៦៥នាក់ ដែលស្នាក់ នៅក្នុងមណ្ឌលកុមារកំព្រា។ បន្ថែមលើសពីនេះទៀត គ្រឹះស្ថានក៏បានបរិច្ចាកថវិការចំនួន ២,៨០០,០០០រៀល ដើម្បីជួសជុលប្រព័ន្ធទឹកស្អាតដែលបានខូចខាតកន្លងមក និងអាចមានទឹកស្អាត អនាម័យ ញាំដូចមុនវិញ និងជួសជុលបង្គន់ និងគ្រែគេងដែរខូចផងដែរ។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី បានប្តេជ្ញាចិត្ត នឹងបន្តចូលរួមចំណែក ក្នុងការជួយដល់កុមារកំព្រានៅកម្ពុជាយើង។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី តែងតែចូលរួមចំណែក និងជួយដល់សហគមន៍ និងសង្គមរបស់យើង ដើម្បីសម្រាលទុក្ខលំបាករបស់ប្រជាពលរដ្ឋ ដែលកំពុងជួបប្រទះការលំបាក។ យើងយល់ពីសារៈសំខាន់នៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសម្រាប់សង្គម ជាពិសេសក្នុងការជួយជនងាយរងគ្រោះ ការលើកកម្ពស់កំណើនជីវភាព ការពង្រឹងសមត្ថភាពសង្គម និងការកសាងសហគមន៍។









## ❖ សប្បុរសធម៌នៅសាលាបឋមសិក្សាត្នោតខ្ពស់ និងសាលាបឋមសិក្សាមាន់ដប់

ដោយមើលឃើញពីសារៈសំខាន់នៃការអប់រំ និងដើម្បីចូលរួមលើកកម្ពស់ដល់វិស័យអប់រំនៅកម្ពុជា គណៈគ្រប់គ្រងនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី បានធ្វើកម្មវិធីសប្បុរសធម៌ដោយនាំយកថវិការមួយចំនួន និង កង្ហារសម្រាប់បំពាក់ក្នុងថ្នាក់រៀន ក៏ដូចជាសម្ភារៈសិក្សាផ្សេងៗទៀតចែកជូនលោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សដែលកំពុងសិក្សានៅ សាលាបឋមសិក្សាត្នោតខ្ពស់ ដែលស្ថិតនៅសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ និងសាលាបឋមសិក្សាមាន់ដប់ ដែលស្ថិតនៅភូមិមាន់ដប់ ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ពិតជាមានសេចក្តីសោមនស្សរីករាយក្នុងការជួយគ្រាំទ្រ និងរួមចំណែកជាមួយសមាគមក្នុងការជួយសម្រួលទុកលំបាកដល់សិស្សានុសិស្សដែលកំពុងជួបប្រទះបញ្ហានាៗ។ យើងនឹងបន្តផ្តល់ជំនួយដល់សាលាផ្សេងៗទៀត ទាំងនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ស្របតាមចក្ខុវិស័យ និងបេសកកម្មរបស់យើង។ យើងជឿជាក់ថាការរួមចំណែករបស់យើងនឹងដើរតួយ៉ាងសំខាន់ក្នុងការជួយដល់ការរីកចម្រើននៃវិស័យអប់រំ និងសាលារៀននៅក្នុងប្រទេសកម្ពុជា ។









# III. សមិទ្ធផលហិរញ្ញវត្ថុរបស់យើង

## ១. សេចក្ដីសង្ខេបអំពីសមិទ្ធផល

### សមតុល្យផលប័ត្រឥណទាន

ទោះបីឆ្នាំ២០២៤ គឺជាឆ្នាំដែលមានវិបត្តិសេដ្ឋកិច្ចពិភពលោកក៏ដោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី នៅតែផ្ដល់ប្រាក់កម្ចីដល់អតិថិជនជាមួយនឹងផលិតផលកម្ចីផ្សេងៗរបស់យើង។ ប៉ុន្តែសម្រាប់ឆ្នាំ២០២៤ ប្រាក់កម្ចីរបស់យើងមានការថយចុះប្រហែល១៨ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំ២០២៣ ជាមួយនឹងផលប័ត្រប្រាក់កម្ចីសរុប ៥០១,២៦៦ដុល្លារ។

| សមតុល្យផលប័ត្រឥណទាន | ២០២៤ | ២០២៣ | បម្រែបម្រួល(ដុល្លារ) | ការប្រែប្រួល (%) |
|---|---|---|---|---|
| សមតុល្យផលប័ត្រឥណទាន(ដុល្លារ) | 501,266 | 614,970 | (113,704) | (18.49%) |




### សមតុល្យផលប័ត្រឥណទានតាមវិស័យ

ក្នុងឆ្នាំនេះ ភាគច្រើននៃការផ្ដល់ប្រាក់កម្ចីរបស់យើង គឺផ្ដល់ទៅលើវិស័យពាណិជ្ជកម្ម និងគេហដ្ឋាន។ ក្នុងចំណោមវិស័យទាំងអស់ ផលប័ត្រឥណទានអាជីវកម្មជាប់ចំណាត់ថ្នាក់កំពូល បន្ទាប់មក គឺផលប័ត្រឥណទានគេហដ្ឋាន។ បើប្រៀបធៀបទៅនឹងឆ្នាំ២០២៣ ផលប័ត្រឥណទានអាជីវកម្មថយចុះប្រហែល២២ភាគរយ ខណៈពេលដែលផលប័ត្រឥណទានគេហដ្ឋានថយចុះប្រហែល៩ភាគរយ។

| លរ. | ប្រភេទវិស័យ | ២០២៤ | ២០២៣ | ការប្រែប្រួល(ដុល្លារ) | ការប្រែប្រួល(%) |
|---|---|---|---|---|---|
| 1 | អាជីវកម្ម | 276,018 | 357,460 | (81,442) | (22.78) |
| 2 | គេហដ្ឋាន និងគ្រួសារ | 194,863 | 215,422 | (20,559) | (9.54) |
| 3 | ផ្សេងៗ | 30,385 | 42,088 | (11,703) | (27.81) |
| | សរុប(ដុល្លារ) | **501,266** | **614,970** | **(113,704)** | **(18.49)** |




## សមតុល្យផលប័ត្រឥណទានតាមប្រភេទផលិតផល

ផលិតផលកម្ចីរបស់យើងរួមមាន កម្ចីអាជីវកម្ម កម្ចីទិញផ្ទះ កម្ចីរថយន្ត និងកម្ចីផ្ទាល់ខ្លួន។ ប្រាក់កម្ចីអាជីវកម្មមានផលប័ត្រឥណទានធំជាងគេនៃផលិតផលប្រាក់កម្ចីសរុបដែលមានប្រហែល៥៥ភាគរយ។ ផ្ទុយទៅវិញ កម្ចីផ្ទាល់ខ្លួន គឺជាកម្ចីដែលមានផលប័ត្រឥណទានទាបជាងគេនៃផលិតផលកម្ចីសរុប មានត្រឹមប្រហែល០.១៦ភាគរយ។

| លរ. | ប្រភេទវិស័យ | ២០២៤ | ២០២៣ | ការប្រែប្រួល(ដុល្លារ) | ការប្រែប្រួល(%) |
|---|---|---|---|---|---|
| 1 | កម្ចីអាជីវកម្ម | 276,018 | 357,460 | (81,442) | (22.78) |
| 2 | កម្ចីគេហដ្ឋាន | 194,086 | 210,971 | (16,885) | (8.00) |
| 3 | កម្ចីរថយន្ត | 30,385 | 42,088 | (11,703) | (27.81) |
| 4 | កម្ចីផ្ទាល់ខ្លួន | 777 | 4,451 | (3,674) | (82.54) |
| | សរុប | **501,266** | **614,970** | **(113,704)** | **(18.49)** |




## សមតុល្យផលប័ត្រឥណទានតាមប្រភេទរូបិយប័ណ្ណ

ជាមួយនឹងចំនួនប្រាក់កម្ចីសរុបចំនួន៥០១.២៦៦ដុល្លារ ស្មើនឹង៨៩,៩៩ភាគរយជាប្រាក់កម្ចីដុល្លារ និង ១០.០១ ភាគរយជាប្រាក់កម្ចីជាប្រាក់រៀល ដែលបានអនុលោមតាមតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា ដែលមានយ៉ាងហោចណាស់១០ភាគរយ។ ទោះបីជាប្រាក់កម្ចីរបស់យើងមានការថយចុះក៏ដោយ ប៉ុន្តែការផ្តល់ប្រាក់កម្ចីជាប្រាក់រៀលនៅតែរក្សាបាននូវអត្រាខ្ពស់ជាង១០ភាគរយ គឺស្មើនឹង១០,០១ភាគរយ។



## តារាងសង្ខេបប្រាក់ចំណេញ និងខាត

ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ដែលប៉ះពាល់ដល់សេដ្ឋកិច្ច និងអាជីវកម្មរបស់ប្រជាជនកម្ពុជាយើង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក បានជួបការលំបាកក្នុងការផ្តល់ប្រាក់កម្ចីដល់អតិថិជន។ ជាលទ្ធផល ប្រាក់កម្ចីរបស់យើងបានធ្លាក់ចុះយ៉ាងខ្លាំងចំនួន១៨,៤៩ភាគរយ ធៀបនឹងឆ្នាំ២០២៣ ដែលធ្វើឱ្យមានការធ្លាក់ចុះនៃប្រាក់ចំណូលរបស់យើងសម្រាប់ឆ្នាំ២០២៤ផងដែរ។

| របាយការណ៍ប្រាក់ចំណេញ និងខាត | ២០២៤ | ២០២៣ | ការប្រែប្រួល(%) |
|---|---|---|---|
| ចំណូលការប្រាក់ | 62,084 | 72,246 | (14.07) |
| ចំណូលផ្សេងៗ | 7,871 | 5,425 | 45.09 |
| **ចំណូលពីប្រតិបត្តិការសុទ្ធ** | **69,955** | **77,671** | **(9.93)** |
| ចំណាយការប្រាក់ | (40,865) | (41,340) | (1.15) |
| ចំណាយប្រតិបត្តិការ | (216,422) | (253,119) | (14.50) |
| សំវិធានធនឥណទានសង្ស័យ និងបាត់បង់ | (64,755) | (79,546) | (18.59) |
| ចំណាយលើការលុបចោលនៃឥណទាន | - | (134,779) | (100.00) |
| **ចំណេញខាតក្នុងឆ្នាំ** | **(252,087)** | **(431,113)** | **(41.53)** |

## តារាងតុល្យការសង្ខេប

ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក បានថយចុះប្រហែល៤០ភាគរយប្រៀបធៀបនឹងឆ្នាំមុន។ ទោះជាយ៉ាងណាក៏ដោយ បំណុលសរុបរបស់យើងបានថយចុះ១៤ភាគរយ ប្រៀបធៀបទៅនឹងឆ្នាំមុន។ ម៉្យាងវិញទៀត បំណុលរបស់ស្ថាប័នយើងគឺបានថយចុះ៤ភាគរយ ប្រៀបធៀបទៅនឹងឆ្នាំ២០២៣។

| តារាងតុល្យការសង្ខេប | ២០២៤ | ២០២៣ | ការប្រែប្រួល(%) |
|---|---|---|---|
| ទ្រព្យសកម្ម | 522,575 | 877,990 | (40.48) |
| ផលប័ត្រកម្ចី | 501,266 | 614,970 | (18.49) |
| បំណុលសរុប | 623,052 | 726,380 | (14.23) |
| បំណុលរបស់ស្ថាប័ន | 608,495 | 636,000 | (4.32) |
| មូលធនភាគទុនិក | (100,477) | 151,610 | (166.27) |

# ២. របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមភ្ជាប់នូវរបាយការណ៍នេះ ជាមួយរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក តទៅហៅថា "ក្រុមហ៊ុន" សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤។

## ១. ព័ត៌មានអំពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ("MOC") ក្រោមលេខចុះបញ្ជីលេខ. ០០០៣៥៣៩៣ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៨។ នៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៨ ក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ក្រុមហ៊ុនក៏បានទទួលការបន្តអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុ ដែលបានអនុម័តដោយ ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២៤។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន ផ្តោតសំខាន់ក្នុងការធ្វើសកម្មភាពអាជីវកម្មមីក្រូហិរញ្ញវត្ថុ និងការផ្តល់សេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងនៅផ្ទះលេខ KH១+KH២ ផ្លូវ១០៥ ភូមិទួលសំពៅ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## ២. លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ និងកិច្ចការរបស់ក្រុមហ៊ុនដល់កាលបរិច្ឆេទនេះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ពុំមានការស្នើសុំបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤ ទេ។

## ៣. ក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅក្នុងអំឡុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ មានដូចខាងក្រោម៖

| **ឈ្មោះ** | **មុខតំណែង** |
|---|---|
| លោក វូ ចិន | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Wu Tzu Yun | អភិបាល |
| លោក Kao Jung Hua | អភិបាលឯករាជ្យ |

## ៤. សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់នៅ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤ បានធ្វើសវនកម្ម ដោយក្រុមហ៊ុន ខេម អឺខោនធីង & ថាកសឺវីស ឯ.ក។

## ៥. ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវជានាទា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងដោយបានបង្ហាញពិតប្រាកដគ្រប់ ទិដ្ឋភាពជាសារវន្តនូវស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការ អាជីវកម្ម និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់នេះ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលក៏តម្រូវឱ្យ៖

- ក) អនុវត្តគោលនយោបាយគណនេយ្យសមស្រប ទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) ដែលតម្រូវឱ្យមានការវិនិច្ឆ័យ និងការប៉ាន់ស្មានដោយសមហេតុផល ហើយបន្ទាប់មកត្រូវអនុវត្តគោលនយោបាយទាំងនោះឱ្យមានសង្គតិភាព
- ខ) អនុលោមតាមតម្រូវការលាតត្រដាងរបស់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់ សហគ្រាសធុនតូច និងមធ្យម (CIFRS for SMEs) និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ហើយប្រសិនជាមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះក្នុងការបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់យោបល់លើចំណុចមិនត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- គ) ថែរក្សាកំណត់ត្រាបញ្ជីគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព
- ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែករណីមិនសមស្របណាកើតឡើង តែយើងសន្មត់ថាក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត និង
- ង) គ្រប់គ្រងផ្ទៃក្នុង និងរាល់ការសម្រេចចិត្តសំខាន់ៗដែលប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ដូច្នេះ ត្រូវប្រាកដថាសេចក្តីសម្រេចទាំងនោះត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលក៏មានទំនួលខុសត្រូវក្នុងការការពារទ្រព្យសកម្មរបស់ក្រុមហ៊ុន ហេតុដូច្នេះហើយ សម្រាប់ការចាត់ វិធានការសមហេតុផលក្នុងការបង្ការ និងការពារការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗទៀត។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ៦. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានយកចិត្តទុកដាក់ទៅលើបញ្ហាដូចខាងក្រោម៖

- ក) ការផ្ទេរជាសារវន្តទាំងអស់ទៅ ឬពីទុនបម្រុង ឬសំវិធានធន ក្នុងអំឡុងពេលឆ្នាំហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- ខ) សំវិធានធនលើឱនភាពតម្លៃនៃឥណទានផ្តល់ដល់អតិថិជន និងទ្រព្យសកម្មរយៈពេលខ្លីនិងវែងត្រូវធ្វើឡើងតាមការតម្រូវ
- គ) បំណុលទារមិនបានដែលទទួលស្គាល់ត្រូវកាត់ចេញ ប្រសិនបើមាន
- ឃ) វិធីសាស្ត្រដែលមានស្រាប់ក្នុងការវាយតម្លៃទ្រព្យសកម្ម ឬបំណុល គឺមិនអាចបំភាន់ ឬមិនសមរម្យទេ

ង) មិនមានករណីណាដែលចំនួនទឹកប្រាក់បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុនាំឱ្យមានការភាន់ច្រឡំនោះទេ

ច) គ្មានប្រតិបត្តិការ ឬព្រឹត្តិការណ៍ជាសារវន្ត និងមិនធម្មតា កើតមានឡើងនៅក្នុងចន្លោះពេលកាលបរិច្ឆេទបញ្ចប់របាយការណ៍ហិរញ្ញវត្ថុ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ អាចប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ឆ្នាំហិរញ្ញវត្ថុនេះឡើយ

ឆ) លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុ គឺមិនរងផលប៉ះពាល់ ដោយមតិយោបល់របស់ក្រុមប្រឹក្សាភិបាលដោយប្រការណាមួយ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ជាសារវន្ត និងមិនប្រក្រតីផ្សេងៗនោះទេ

ជ) គ្មានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុនដែលអាចបង្ខំឱ្យអនុវត្ត ឬទំនងជាអាចអនុវត្តបានក្នុងរយៈពេលដប់ពីរខែ បន្ទាប់ពីចុងការិយបរិច្ឆេទបញ្ចប់នៃឆ្នាំហិរញ្ញវត្ថុ អាចធ្វើឱ្យប៉ះពាល់ដល់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចសង នៅពេលបំណុលដែលដល់កាលកំណត់ឡើយ ។

## ៧. ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងនាមក្រុមប្រឹក្សាភិបាលនៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក ខ្ញុំសូមបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ត្រូវបានបង្ហាញពិតប្រាកដគ្រប់ទិដ្ឋភាពជាសារវន្ត រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ និងរបាយការណ៍ចំណេញ ខាត និងចំណូលពេញលេញផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs) និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា (“NBC”)។

តំណាងក្រុមប្រឹក្សាភិបាល

WU CHEN

FAMILY MICROFINANCE PLC. KINGDOM OF CAMBODIA

លោក វូ ចិន

ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២៥

# ៣. របាយការណ៍ហិរញ្ញវត្ថុសវនកម្មឯករាជ្យ
## ជូនចំពោះភាគទុនិករបស់
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក

### មតិយោបល់

យើងបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ ព្រមទាំងរបាយការណ៍ចំណេញខាត និងចំណូល ពេញលេញផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ ដូចមានបង្ហាញក្នុងទំព័រលេខ ៨ ដល់លេខ ៤០។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយត្រូវបានបង្ហាញពិតប្រាកដគ្រប់ទិដ្ឋភាពជា សារវន្តលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុនិងលំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs) រួមជាមួយសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា (“NBC”)។

### មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“ស.ស.អ.ក”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុក្នុងរបាយការណ៍នេះ។ យើងជឿថាភស្តុតាងសវនកម្មដែលយើងទទួលបាន គឺគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

### ឯករាជ្យភាព

យើងមានភាពឯករាជ្យពីក្រុមហ៊ុនដោយអនុលោមទៅតាមស្តង់ដារក្រមសីលធម៌គណនេយ្យករអន្តរជាតិ សម្រាប់ក្រមសីលធម៌វិជ្ជាជីវៈគណនេយ្យករអន្តរជាតិ ដែលចេញដោយក្រុមប្រឹក្សាស្តង់ដារនៃក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ (IESBA) រួមជាមួយនឹងតម្រូវការក្រមសីលធម៌របស់គណនេយ្យករជំនាញ និងសវនករនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (វ.គ.ស.ក.) ដែលពាក់ព័ន្ធនឹងសវនកម្មនៃរបាយការណ៍ហិរញ្ញវត្ថុរបស់យើងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ យើងបានបំពេញនូវទំនួលខុសត្រូវប្រកបដោយក្រមសីលធម៌ផ្សេងទៀតរបស់យើងតាម (IESBA) និង (វ.គ.ស.ក.)។

## ការសង្កត់ធ្ងន់លើបញ្ហា

### ១-មូលដ្ឋានបន្តនិរន្តរភាពៈ

យើងសូមទាញចំណាប់អារម្មណ៍លើកំណត់សម្គាល់លេខ ៤.១ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលបង្ហាញថាក្រុមហ៊ុនបានខាតបង្គរចំនួន ១.៦៤៣.៥៣៧ ដុល្លារអាមេរិក ហើយគិតត្រឹមកាលបរិច្ឆេទនោះ បំណុលសរុបរបស់ក្រុមហ៊ុនមានលើសពីទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនចំនួន ១០០.៤៧៧ ដុល្លារអាមេរិក។ លក្ខខណ្ឌទាំងនេះ បង្ហាញថា ភាពមិនច្បាស់លាស់ជាសារវន្តបានកើតមានឡើង ដែលអាចធ្វើឱ្យមានការសង្ស័យ ចំពោះសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម។ មតិយោបល់របស់យើងមិនត្រូវបានកែប្រែចំពោះបញ្ហានេះទេ។

### ២-ពន្ធពន្យារជាទ្រព្យសកម្មៈ

យើងសូមទាញចំណាប់អារម្មណ៍លើកំណត់សម្គាល់លេខ ៤.២ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលក្រុមហ៊ុនមិនបានទទួលស្គាល់ពន្ធពន្យារជាទ្រព្យសកម្ម ដោយសារតែនឹងមិនអាចមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដើម្បីប្រើប្រាស់ទ្រព្យសកម្ម។ មតិយោបល់របស់យើងមិនត្រូវបានកែប្រែចំពោះបញ្ហានេះទេ។

## ព័ត៌មានផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាមីលី ម.ក សម្រាប់ការិយបរិច្ឆេទបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មមួយផ្សេងទៀតដែលរបាយការណ៍ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥ បានបង្ហាញមតិយោបល់ពិតប្រាកដ និង ត្រឹមត្រូវ។

## ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន គឺជាអ្នកទទួលខុសត្រូវរាល់ព័ត៌មានដែលជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន។ ព័ត៌មាននោះរួមបញ្ចូលទាំងរបាយការណ៍ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនបានរួមបញ្ចូលជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនករឡើយ។

ការបញ្ចេញទស្សនៈរបស់ពួកយើងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺមិនបានរាប់បញ្ចូលជាមួយរបាយការណ៍ក្រុមប្រឹក្សាភិបាលឡើយ ហើយពួកយើងក៏មិនបញ្ចេញមតិលើរបាយការណ៍នេះដែរ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ទំនួលខុសត្រូវរបស់សវនករ គឺគ្រាន់តែអានពី របាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងពិចារណាថា តើរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានភាពមិនស៊ីសង្វាក់គ្នាខ្លាំងជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬក៏ការយល់ដឹងរបស់យើងដែលទទួលបានក្នុងអំឡុងពេលធ្វើ សវនកម្មទំនងជាបង្ហាញពីកំហុសជាសារវន្ត។

ប្រសិនបើយោងទៅតាមការងារដែលពួកយើងបានបំពេញ រួចសន្និដ្ឋានថា របាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានកំហុសជាសារវន្ត ដែលតម្រូវអោយយើងរាយការណ៍ពីការពិតនេះ។ យើងគ្មានអ្វីដែលត្រូវរាយការណ៍ពីបញ្ហានេះឡើយ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលនៅលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធនតូច និងមធ្យម (CIFRS for SMEs) និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនទទួលខុសត្រូវដូចគ្នាផងដែរ ចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលក្រុមហ៊ុនយល់ថា មានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការវាយតម្លៃនិរន្តរភាពរបស់ក្រុមហ៊ុន លាតត្រដាងរាល់បញ្ហា ដែលមានជាប់ពាក់ព័ន្ធជាមួយនឹងនិរន្តរភាពរបស់ក្រុមហ៊ុននិងការប្រើប្រាស់មូលដ្ឋាននិរន្តរភាព លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់បិទក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសពិតប្រាកដក្រៅពីធ្វើដូច្នេះ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងគឺ ដើម្បីទទួលបាននូវការធានាសមហេតុផលអំពីរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូល មិនមានកំហុសឆ្គងជាសារវន្ត មិនថាដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំ និងការចេញរបាយការណ៍សវនករដែលរាប់បញ្ចូលទាំងទស្សនៈរបស់យើង។ ការធានាសមហេតុផលគឺជាកម្រិតខ្ពស់នៃការធានា ប៉ុន្តែមិនធានាថាសវនកម្មដែលធ្វើឡើងស្របតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“ស.ស.អ.ក”) នឹងរកឃើញកំហុសជាសារវន្ត នៅពេលកើត ឡើងនោះទេ។ ការបំភាន់អាចកើតឡើងពីការក្លែងបន្លំ ឬកំហុសហើយត្រូវបានគេចាត់ទុកថាជាសារវន្ត ក្នុងមួយឬច្រើនករណីបូកបញ្ចូលគ្នា ដែលករណីទាំងនេះអាចជះឥទ្ធិពលដល់ការសម្រេចចិត្តខាងសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដែលផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃសវនកម្មស្របតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“ស.ស.អ.ក”) យើងអនុវត្តការវិនិច្ឆ័យប្រកប ដោយវិជ្ជាជីវៈ និងរក្សានូវជំនាញវិជ្ជាជីវៈក្នុងការធ្វើសវនកម្មទាំងមូល។ យើងក៏៖

(ក) កំណត់និងវាយតម្លៃហានិភ័យនៃភាពមិនត្រឹមត្រូវជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមិនថាដោយសារការក្លែងបន្លំឬកំហុស រៀបចំនិងអនុវត្តនីតិវិធីសវនកម្មឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបានភស្តុតាងសវនកម្មដែលមានលក្ខណៈគ្រប់គ្រាន់នឹងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ទស្សនៈរបស់យើង។ ហានិភ័យដែលមិនរកឃើញកំហុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាងកំហុសដែលបណ្តាលមកពីកំហុស ការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំ ការលុបចោលដោយចេតនា ការលាតត្រដាងមិនពិត ឬការរំលោភប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង។

(ខ) ទទួលបានការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងសវនកម្មដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របក្នុងកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

(គ) វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលបានប្រើនិងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងដែលពាក់ព័ន្ធដែលធ្វើឡើងដោយអ្នកគ្រប់គ្រង។

(ឃ) សន្និដ្ឋានលើភាពសមស្របការប្រើប្រាស់របស់អភិបាលលើមូលដ្ឋាននិរន្តរភាពនៃគណនេយ្យ និងផ្អែកលើភស្តុតាងសវនកម្ម ដែលទទួលបានថា តើភាពមិនច្បាស់លាស់ជាសារវន្តមានទាក់ទងនឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌ ដែលអាចធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងចំពោះសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ប្រសិនបើយើងសន្និដ្ឋានថាមានភាពមិនច្បាស់លាស់ជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលទៅក្នុងរបាយការណ៍របស់សវនកររបស់យើង ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុ ឬបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ផ្តល់មតិសវនកម្មដែលមានបញ្ហា។

ការសន្និដ្ឋានរបស់យើងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើង។ ទោះយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពអាជីវកម្ម។

(ង) វាយតម្លៃការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានការលាតត្រដាងថាតើរបាយការណ៍ហិរញ្ញវត្ថុមានប្រតិបត្តិការនិងព្រឹត្តិការណ៍ទាំងនោះបង្ហាញដោយត្រឹមត្រូវឬទេ។

យើងបានផ្តល់ព័ត៌មានជូនក្រុមប្រឹក្សាភិបាល ស្តីពីបញ្ហាផ្សេងៗ វិសាលភាពនិងពេលវេលាដែលបានគ្រោងទុកសម្រាប់ធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលមានរួមបញ្ចូលទាំងចំនុចខ្វះខាតក្នុងការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលសវនកម្មរបស់យើង។

តំណាងឱ្យក្រុមហ៊ុន ខេម អឹខោនធីង & ថាកសឺវីស
ស្នងការគណនេយ្យ និងសវនកម្ម

**តាត ហេង, CPA, FCCA**
**នាយកសវនកម្ម**

រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០២៥

# ៤. របាយការណ៍សវនកម្មហិរញ្ញវត្ថុ

## ❖ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

**សម្រាប់ការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤**

| | | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យ និងគ្រឿងបរិក្ខារ | ១០ | ៧.៧៥៥ | ៣១.២១៤ | ៩.៤៦៣ | ៣៨.៦៥៦ |
| ឥណទានផ្តល់ដល់អតិថិជន | ៨ | ៣៤០.៣៩៥ | ១.៣៧០.០៩០ | ៥២២.២៧៧ | ២.១៣៣.៥០២ |
| **សរុបទ្រព្យសកម្មរយៈពេលវែង** | | ៣៤៨.១៥០ | ១.៤០១.៣០៤ | ៥៣១.៧៤០ | ២.១៧២.១៥៨ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | ១.២៧១ | ៥.១១៦ | ២.១៩២ | ៨.៩៥៤ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារជាតិនៃកម្ពុជា | ៦ | ៨៤.៩៤៨ | ៣៤១.៩១៦ | ៧៦.៤៨៣ | ៣១២.៤៣៣ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ | ៧ | ៨៧.០៥៦ | ៣៥០.៤០០ | ២៦៦.៧៩៥ | ១.០៨៩.៨៥៨ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ១.១៥០ | ៤.៦២៩ | ៧៨០ | ៣.១៨៦ |
| **សរុបទ្រព្យសកម្មរយៈពេលខ្លី** | | ១៧៤.៤២៥ | ៧០២.០៦១ | ៣៤៦.២៥០ | ១.៤១៤.៤៣១ |
| **សរុបទ្រព្យសកម្ម** | | **៥២២.៥៧៥** | **២.១០៣.៣៦៥** | ៨៧៧.៩៩០ | ៣.៥៨៦.៥៨៩ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចីពីសម្ព័ន្ធញាតិ | ២០ | ៦០៨.៤៩៥ | ២.៤៤៩.១៩២ | ៦៣៦.០០០ | ២.៥៩៨.០៦០ |
| **សរុបបំណុលរយៈពេលវែង** | | ៦០៨.៤៩៥ | ២.៤៤៩.១៩២ | ៦៣៦.០០០ | ២.៥៩៨.០៦០ |
| **បំណុលរយៈពេលខ្លី** | | | | | |
| បំណុលផ្សេងៗ | ១១ | ១៤.៥៥៧ | ៥៨.៥៩២ | ៩០.៣៨០ | ៣៦៩.២០២ |
| **សរុបបំណុលរយៈពេលខ្លី** | | ១៤.៥៥៧ | ៥៨.៥៩២ | ៩០.៣៨០ | ៣៦៩.២០២ |
| **សរុបបំណុល** | | **៦២៣.០៥២** | **២.៥០៧.៧៨៤** | ៧២៦.៣៨០ | ២.៩៦៧.២៦២ |
| **មូលធន** | | | | | |
| ដើមទុន | ១២ | ១.៥០០.០០០ | ៦.០០០.០០០ | ១.៥០០.០០០ | ៦.០០០.០០០ |
| ទុនបម្រុងបទប្បញ្ញត្តិ | ១៣ | ៤៣.០៦០ | ១៧២.០៧៥ | ៧១.៥៣៦ | ២៨៨.០០១ |
| ខាតបង្គរ | | (១.៣៩១.៤៥០) | (៥.៦៧៤.៤៣៣) | (៩៨៨.៨១៣) | (៤.០១៨.៤៨៥) |
| ខាតក្នុងឆ្នាំ | | (២៥២.០៨៧) | (១.០២៦.២៤៦) | (៤៣១.១១៣) | (១.៧៧១.៨៧៤) |
| លម្អៀងពីអត្រាប្តូរប្រាក់ | | - | ១២៤.១៨៥ | - | ១២១.៦៨៥ |
| **សរុបមូលធន** | | **(១០០.៤៧៧)** | **(៤០៤.៤១៩)** | ១៥១.៦១០ | ៦១៩.៣២៧ |
| **សរុបបំណុល និង មូលធន** | | **៥២២.៥៧៥** | **២.១០៣.៣៦៥** | ៨៧៧.៩៩០ | ៣.៥៨៦.៥៨៩ |

## ❖ របាយការណ៍ចំណូលលម្អិត

### សម្រាប់ការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤

| | | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ១៤ | ៦២.០៨៤ | ២៥២.៧៤៤ | ៧២.២៤៦ | ២៩៦.៩៣១ |
| ចំណាយការប្រាក់ | ១៥ | (៤០.៨៦៥) | (១៦៦.៣៦១) | (៤១.៣៤០) | (១៦៩.៩០៧) |
| **ចំណូលការប្រាក់សុទ្ធ** | | **២១.២១៩** | **៨៦.៣៨៣** | ៣០.៩០៦ | ១២៧.០២៤ |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ១៦ | **៧.៨៧១** | **៣២.០៤៣** | ៥.៤២៥ | ២២.២៩៧ |
| ចំណាយបុគ្គលិក | ១៧ | (១៥៣.២២១) | (៦២៣.៧៦៣) | (១៨០.១៣៣) | (៧៤០.៣៤៧) |
| ចំណាយរំលស់ទ្រព្យសកម្មរូបី | ១០ | (១.៧០៨) | (៦.៩៥៣) | (៧៧៤) | (៣.១៨១) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ១៨ | (៦០.៧៨៥) | (២៤៧.៤៥៦) | (២០៥.៧៤៦) | (៨៤៥.៦១៦) |
| សំវិធានធនលើឱនភាពតម្លៃ | ១៩ | (៦៤.៧៥៥) | (២៦៣.៦១៨) | (៧៩.៥៤៥) | (៣២៦.៩៣០) |
| **ខាតមុនបង់ពន្ធ** | | **(២៥១.៣៧៩)** | **(១.០២៣.៣៦៤)** | (៤២៩.៨៦៧) | (១.៧៦៦.៧៥៣) |
| ពន្ធលើប្រាក់ចំណូល | ២១ | (៧០៨) | (២.៨៨២) | (១.២៤៦) | (៥.១២១) |
| **ខាតក្នុងឆ្នាំ** | | **(២៥២.០៨៧)** | **(១.០២៦.២៤៦)** | (៤៣១.១១៣) | (១.៧៧១.៨៧៤) |
| ប្រាក់ចំណេញពេញលេញផ្សេងៗ | | - | - | - | - |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | | - | ២.៥០០ | - | (៧.៨៧០) |
| **សរុបប្រាក់ចំណេញពេញលេញក្នុងឆ្នាំ** | | **(២៥២.០៨៧)** | **(១.០២៣.៧៤៦)** | (៤៣១.១១៣) | (១.៧៧៩.៧៤៤) |

## ❖ របាយការណ៍លំហូរសាច់ប្រាក់

### សម្រាប់ការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤

| | សម្គាល់ | ២០២៤ | | ២០២៣ | |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិ** | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ខាតមុនបង់ពន្ធ | | (២៥១.៣៧៩) | (១.០២៣.៣៦៤) | (៤២៩.៨៦៧) | (១.៧៦៦.៧៥២) |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់ | ១០ | ១.៧០៨ | ៦.៩៥៣ | ៧៧៤ | ៣.១៨១ |
| សំវិធានធនលើឱនភាពតម្លៃ | ១៩ | ៦៤.៧៥៥ | ២៦៣.៦១៨ | ៧៩.៥៤៥ | ៣២៦.៩៣០ |
| ចំណាយការប្រាក់ | ១៥ | ៤០.៨៦៥ | ១៦៦.៣៦១ | ៤១.៣៤០ | ១៦៩.៩០៧ |
| **ប្រតិបត្តិការខាតមុនបម្រែបម្រួលទុនបង្វិល** | | (១៤៤.០៥១) | (៥៨៦.៤៣២) | (៣០៨.២០៨) | (១.២៦៦.៧៣៤) |
| **បម្រែបម្រួល៖** | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | ៨ | ១១៥.៣១២ | ៤៦៩.៤៣៥ | ២៤៣.៤០៥ | ៩៩៤.៣០៩ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | (៣៦៩) | (១.៥០២) | ១០.២៧០ | ៤១.៩៥៣ |
| បំណុលផ្សេងៗ | ១១ | (៧៥.៨២៣) | (៣០៨.៦៧៥) | ៣៤.១០៤ | ១៣៩.៣១៥ |
| **លំហូរសាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | | (១០៤.៩៣១) | (៤២៧.១៧៤) | (២០.៤២៩) | (៩១.១៥៧) |
| ពន្ធលើប្រាក់ចំណូល | ២១ | (៧០៨) | (២.៨៨២) | (១.២៤៦) | (៥.១២១) |
| **លំហូរសាច់ប្រាក់សុទ្ធដែលប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | (១០៥.៦៣៩) | (៤៣០.០៥៦) | (២១.៦៧៥) | (៩៦.២៧៨) |
| **លំហូរសាច់ប្រាក់ត្រូវបានប្រើក្នុងសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងគ្រឿងបរិក្ខារ | ១០ | - | - | (១.០៣៨) | (៤.២៤០) |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិជាមួយធនាគារជាតិនៃកម្ពុជា | ៦ | (៧.៥០០) | (៣០.៥៣៣) | - | - |
| **លំហូរសាច់ប្រាក់សុទ្ធត្រូវបានប្រើក្នុងសកម្មភាពវិនិយោគ** | | (៧.៥០០) | (៣០.៥៣៣) | (១.០៣៨) | (៤.២៤០) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ទឹកប្រាក់ទទួលពីកម្ចី | ២០ | (២៧.៥០៥) | (១១១.៩៧៣) | - | - |
| ការប្រាក់បានបង់ | ១៥ | (៤០.៨៦៥) | (១៦៦.៣៦១) | (៤១.៣៤០) | (១៦៩.៩០៧) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន** | | (៦៨.៣៧០) | (២៧៨.៣៣៤) | (៤១.៣៤០) | (១៦៩.៩០៧) |
| **ការផ្លាស់ប្តូរសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | (១៨១.៥០៩) | (៧៣៨.៩២៣) | (៦៤.០៥៣) | (២៧០.៤២៥) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី០១ ខែមករា** | | ២៧៣.១៦៧ | ១.១១៥.៨៨៧ | ៣៣៧.២២០ | ១.៣៨៨.៣៣៤ |
| **លម្អៀងពីបង្គរការប្រែសម្រួលរូបិយប័ណ្ណ** | | - | (៨.០៤១) | - | (២.០២២) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី៣១ ខែធ្នូ** | | ៩១.៦៥៨ | ៣៦៨.៩២៣ | ២៧៣.១៦៧ | ១.១១៥.៨៨៧ |

**ការផ្ទៀងផ្ទាត់នូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤ និងឆ្នាំ ២០២៣÷**

| | ២០២៤ | | ២០២៣ | |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ១.២៧១ | ៥.១១៦ | ២.១៩២ | ៨.៩៥៤ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារជាតិនៃកម្ពុជា (មិនរាប់បញ្ចូលប្រាក់តម្កល់តាមបទប្បញ្ញត្តិ) | ២.៤៤៨ | ៩.៨៥៣ | ១.៤៨៣ | ៦.០៥៨ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ជាមួយធនាគារផ្សេងៗ | ៨៧.៩៣៩ | ៣៥៣.៩៥៤ | ២៦៩.៤៩២ | ១.១០០.៨៧៥ |
| | **៩១.៦៥៨** | **៣៦៨.៩២៣** | ២៧៣.១៦៧ | ១.១១៥.៨៨៧ |

## ❖ របាយការណ៍បម្រែបម្រួលមូលធន

**សម្រាប់ការិយបរិច្ឆេទថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤**

| | មូលធន | ទុនបម្រុង បទប្បញ្ញត្តិ | ខាតបង្គរ | សរុប |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| សមតុល្យថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២៣ | ១.៥០០.០០០ | ២១៦.១៦៣ | (១.១៣៣.៤៤០) | ៥៨២.៧២៣ |
| ខាតក្នុងឆ្នាំ | - | - | (៤៣១.១១៣) | (៤៣១.១១៣) |
| ការផ្ទេរ | - | (១៤៤.៦២៧) | ១៤៤.៦២៧ | - |
| សមតុល្យថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៣ | ១.៥០០.០០០ | ៧១.៥៣៦ | (១.៤១៩.៩២៦) | ១៥១.៦១០ |
| **ខាតក្នុងឆ្នាំ** | - | - | (**២៥២.០៨៧**) | (**២៥២.០៨៧**) |
| **ការផ្ទេរ** | - | (**២៨.៤៧៦**) | **២៨.៤៧៦** | - |
| **សមតុល្យថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៤** | **១.៥០០.០០០** | **៤៣.០៦០** | (**១.៦៤៣.៥៣៧**) | (**១០០.៤៧៧**) |

| | មូលធន | ទុនបម្រុង បទប្បញ្ញត្តិ | ខាតបង្គរ | លម្អៀងអត្រា ប្តូរប្រាក់ | សរុប |
|---|---|---|---|---|---|
| | ខ្មែរពាន់រៀល | ខ្មែរពាន់រៀល | ខ្មែរពាន់រៀល | ខ្មែរពាន់រៀល | ខ្មែរពាន់រៀល |
| សមតុល្យថ្ងៃទី ០១ ខែមករា ឆ្នាំ ២០២៣ | ៦.០០០.០០០ | ៨៨២.៤១៨ | (៤.៦១២.៩០២) | ១២៩.៥៥៥ | ២.៣៩៩.០៧១ |
| ខាតក្នុងឆ្នាំ | - | - | (១.៧៧១.៨៧៤) | - | (១.៧៧១.៨៧៤) |
| ការផ្ទេរ | - | (៥៩៤.៤១៧) | ៥៩៤.៤១៧ | - | - |
| លម្អៀងពីអត្រាប្តូរប្រាក់ | - | - | - | (៧.៨៧០) | (៧.៨៧០) |

| | | | | | |
|---|---|---|---|---|---|
| សមតុល្យថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៣ | ៦.០០០.០០០ | ២៨៨.០០១ | (៥.៧៩០.៣៥៩) | ១២១.៦៨៥ | ៦១៩.៣២៧ |
| | | | | | |
| **ខាតក្នុងឆ្នាំ** | - | - | **(១.០២៦.២៤៦)** | - | **(១.០២៦.២៤៦)** |
| **ការផ្ទេរ** | - | **(១១៥.៩២៦)** | **១១៥.៩២៦** | - | - |
| **លម្អៀងពីអត្រាប្តូរប្រាក់** | - | - | - | **២.៥០០** | **២.៥០០** |
| **សមតុល្យថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៤** | **៦.០០០.០០០** | **១៧២.០៧៥** | **(៦.៧០០.៦៧៩)** | **១២៤.១៨៥** | **(៤០៤.៤១៩)** |

“ ធ្វើឲ្យគ្រួសាររបស់អ្នកកាន់តែប្រសើរឡើង ”

023 901 688
070 911 688
infor@familymfi.com.kh
www.familymfi.com.kh
Family Microfinance PLC